N.22
15.6.02

# ក

## មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រឹត្យ


០៨-៦-២០០២ - ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥០ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ជីន សៀងឈីញ** (JIN XIANGQIN) សញ្ជាតិដើមចិន ១៤៧៥


## II- រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


១០-៦-២០០២ -អនុក្រឹត្យលេខ ៥០ អនក្រ .បក ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ១៤៧៦

១១-៦-២០០២ -អនុក្រឹត្យលេខ ៥១ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា ១៤៨០

១១-៦-២០០២ -អនុក្រឹត្យលេខ ៥២ អនក្រ .បក ស្តីពីការ ផ្ទេរឥណទានថវិកា ១៤៨២

១៣-៦-២០០២ -អនុក្រឹត្យលេខ ៥៣ អនក្រ .បក ស្តីពីការ ផ្ទេរឥណទានថវិកា ១៤៨៤

១៣-៦-២០០២ -អនុក្រឹត្យលេខ ៥៤ អនក្រ .បក ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ ១៤៨៦

១៤-៦-២០០២ -អនុក្រឹត្យលេខ ៥៥ អនក្រ .បក ស្តីពីទទួលស្គាល់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ១៤៩៣

១៤-៦-២០០២ -អនុក្រឹត្យលេខ៥៦អនក្រ.បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យចំរើនពហុបច្ចេកវិជ្ជា ១៤៩៦

០៧-៦-២០០២ -អនុក្រឹត្យលេខ ២៨២ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៩៩

១១-៦-២០០២ -អនុក្រឹត្យលេខ ២៨៣ អនក្រ .តត ស្តីពីការតែងតាំងនិងសំរួលភារកិច្ចមន្ត្រីរាជការ ១៥០០

១១-៦-២០០២ -អនុក្រឹត្យលេខ ២៨៤ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥០១

១១-៦-២០០២ -អនុក្រឹត្យលេខ ២៨៥ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥០២

១២-៦-២០០២ -អនុក្រឹត្យលេខ ២៨៦ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥០៣

១២-៦-២០០២ -អនុក្រឹត្យលេខ ២៨៧ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥០៤

១២-៦-២០០២ -អនុក្រឹត្យលេខ ២៨៨ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥០៥

១២-៦-២០០២ -អនុក្រឹត្យលេខ ២៨៩ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥០៦

១៣-៦-២០០២ -អនុក្រឹត្យលេខ ២៩០ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥០៨

១៣-៦-២០០២ -អនុក្រឹត្យលេខ ២៩១ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥១០

១៣-៦-២០០២ -អនុក្រឹត្យលេខ ២៩២ អនក្រ .តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលប្រចាំសាលាជាតិកសិកម្មកំពង់ចាម ១៥១២

១៣-៦-២០០២ -អនុក្រឹត្យលេខ ២៩៣ អនក្រ .តត ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ១៥១៤

១៤-៦-២០០២ -អនុក្រឹត្យលេខ ២៩៤ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥១៥

១៤-៦-២០០២ -អនុក្រឹត្យលេខ ២៩៥ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥១៦

១៤-៦-២០០២ -អនុក្រឹត្យលេខ ២៩៦ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥១៧

## III- ការិយាល័យក្រសួង

### ១- ធនាគារជាតិ នៃ កម្ពុជា

០៧-៦-២០០២ -ប្រកាសលេខ ធ ៧.០២-១៤៥ប្រក ស្តីពីវិសោធនកម្មលើប្រកាសលេខ ធ ៧-០០-៥១ប្រក ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យ រួមទាំងការប្រាក់ ដែលបានព្យួរ ១៥១៨

០៧-៦-២០០២ -ប្រកាសលេខ ធ ៧-០២-១៤៦ ប្រក ស្តីពី វិសោធនកម្ម លើប្រកាស លេខ ធ ០១-១៣៧ប្រក ស្តីពីឥណទាន ចំពោះសម្ព័ន្ធញាតិ ១៥២២

១៤-៦-២០០២ -ប្រកាសលេខ ធ ៨.០២-១៤៩ ប្រក ស្តីពី រចនាសម្ព័ន្ធរបស់ នាយកដ្ឋាន គ្រប់គ្រងការប្តូរប្រាក់ និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ ១៥២៦

១៤-៦-២០០២ -ប្រកាសលេខ ធ ៨-០២-១៥០ ប្រក ស្តីពី រចនាសម្ព័ន្ធរបស់ នាយកដ្ឋាន គណនេយ្យ និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ ១៥៣៤

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម

១៣-៦-២០០២ - ប្រកាសលេខ ១៦១ MoC/M2002 ស្តីពីការផ្ទេរទ្រព្យសម្បត្តិអចលនវត្ថុ ១៥៤១

១៣-៦-២០០២ - ប្រកាសលេខ ១៦២ MoC/M2002 ស្តីពីការបង្កើតគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ១៥៤២

### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

០៦-៦-២០០២ - ប្រកាសលេខ ១៥៦ បទ.ប្រក ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យការប្រើប្រាស់រលកអាកាសវិទ្យុ ១៥៤៤

០៧-៦-២០០២ - ប្រកាសលេខ ១៥៧ បទ.ប្រក ស្តីពីការបង្កើតគណៈកម្មការដើម្បីត្រួតពិនិត្យការជីកកប់ប្រព័ន្ធទឹកស្អាតតាមនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ១៥៤៧

០៧-៦-២០០២ - ប្រកាសលេខ ១៥៩ បទ.ប្រក ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យចំណូលចំណាយអាជីវកម្មសេវាកម្ម នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ទូទាំងខេត្ត-ក្រុង ១៥៤៩

### ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

១០-៦-២០០២ -ប្រកាសលេខ ១៤២ សកបយ ស្តីពីការបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍ ដើម្បីឱ្យបានឈប់សំរាកបន្ថែមនារសៀលថ្ងៃសៅរ៍ ១៥៥១

# គ


១០-៦-២០០២ - ប្រកាសលេខ ១៤៣ សកបយ ស្តីពីការបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតាដោយគិតជាមធ្យមចំនួន ១២ សប្តាហ៍បន្តបន្ទាប់ ១៥៥៣

១០-៦-២០០២ - ប្រកាសលេខ ១៤៤ សកបយ ស្តីពីបដិប្បញ្ញត្តិចំពោះការហាមឃាត់មិនឱ្យក្មេងធ្វើការពេលយប់ ១៥៥៦

១០-៦-២០០២ - ប្រកាសលេខ ១៤៥ សកបយ ស្តីពីការហ្វឹកហ្វឺនវិជ្ជាជីវៈ ដល់ក្មេងសំរាប់ធ្វើការក្រោមដី ១៥៥៨

**២. ទីស្តីការរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា**

០៦-៦-២០០២ - ប្រកាសលេខ ៤៥០ អយក.ប្រក ស្តីពីបទបញ្ជាជ្រើសរើសនិស្សិតឱ្យចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ១៥៦១

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០២

ព្រះរាជបន្ទូល

មាត្រា១ .- ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ជីង ស៊ាងឈិញ (JIN XIANGQIN) សញ្ជាតិដើមចិន កើតថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៤៣ នៅខេត្ត ZHEJIANG ប្រទេសចិន ។

មាត្រា២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ១៣៧/ច.ល

ភរល-០២.០៦.០០១៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សភាឌី តាន់

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមអ្នកច្បាប់និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងអាស៊ាន ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១.-**

ត្រូវបានកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ដែលមានខុទ្ទកាល័យរដ្ឋមន្ត្រី និងនាយកដ្ឋានបីចំណុះដូចខាងក្រោម :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន
-នាយកដ្ឋានកិច្ចការរដ្ឋបាល
-នាយកដ្ឋានសរុប និងស្ថិតិ

**មាត្រា២.-**

ខុទ្ទកាល័យរដ្ឋមន្ត្រីមានភារកិច្ចដូចមានចែងក្នុងមាត្រា១៧ ជំពូកទី៦ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

**មាត្រា៣.-**

រក្សារចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ានដូចមានចែងក្នុងអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ នៅដដែល ។

**មាត្រា៤.-**

នាយកដ្ឋានកិច្ចការរដ្ឋបាល មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សំរបសំរួលសកម្មភាពការងាររដ្ឋបាលរបស់ក្រសួង ជាមួយអង្គភាពចំណុះក្រសួង ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងចាត់ចែងការការពារសន្តិសុខក្នុងទីស្តីការក្រសួង ។
- សហការរៀបចំការប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា និងពិធីបុណ្យផ្សេងៗរបស់ក្រសួង ។
- រៀបចំ តុបតែង ថែទាំ គ្រប់គ្រងទីស្តីការក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើការបែងចែកសំភារៈ ថវិកា របស់អគ្គលេខាធិការដ្ឋាន ក្រសួង ដល់អង្គភាពក្រោមឱវាទ ។
- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការស៊ីវិល និងនគរបាល ចំណុះអគ្គលេខាធិការដ្ឋានក្រសួង ។
- ធ្វើការងារផ្សេងៗ ទៀត ដែលថ្នាក់ដឹកនាំក្រសួង ឬ អគ្គលេខាធិការដ្ឋានប្រគល់អោយ ។

**មាត្រា៥.-**

នាយកដ្ឋានកិច្ចការរដ្ឋបាលត្រូវបានដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

**មាត្រា៦.-**

នាយកដ្ឋានសរុប និងស្ថិតិមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

-រៀបចំចាត់ចែងធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងលើកទិសដៅការងាររួមប្រចាំអឌ្ឍមាស ខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំរបស់ក្រសួង ។

-រៀបចំកសាងស្ថិតិ សន្ទស្សន៍ការងារសំខាន់ៗ និងចងក្រងឯកសារនានា សំរាប់បំរើការធ្វើសន្និបាត និងកិច្ចប្រជុំសំខាន់ៗផ្សេងទៀត របស់ក្រសួង ។

-ទំនាក់ទំនង និងសហការជាមួយក្រសួងស្ថាប័ន អង្គការសង្គមនានា អង្គភាពចំណុះក្រសួង ខេត្ត ក្រុង ដើម្បីក្តាប់ និងប្រមូលសភាពការណ៍ជាក់ស្តែង ដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ក្រសួង ។

-ពិនិត្យតាមដានការអនុវត្តនូវរាល់បទបញ្ជា សារាចរ សេចក្តីណែនាំ...របស់ក្រសួង ។

-សរុបពតិមាន អត្ថបទពតិមាន ដែលពាក់ព័ន្ធដល់សមត្ថកិច្ចរបស់ក្រសួង ។

**មាត្រា៧.-**

នាយកដ្ឋានសរុប និងស្ថិតិ ត្រូវបានដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជា ជំនួយការ ។

**មាត្រា៨.-**

ការរៀបចំតួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ចំណុះនាយកដ្ឋានកិច្ចការរដ្ឋបាល និងនាយកដ្ឋានសរុប និងស្ថិតិ ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង យូ ហុកគ្រី**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប " ។

-ដូចមាត្រា ១០ "*ដើម្បីអនុវត្ត*" ។

-ឯកសារ កាលប្បវត្តិ ។

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..៥០...អនក្រ.បក

ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

ឃុំ. ពុក់វឌ្ឍី

**អង្គការលេខ របស់អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ**

# អគ្គលេខាធិការដ្ឋាន

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- **នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងអាស៊ាន**
  - កា.រិ.រដ្ឋបាលសរុប
  - កា.រិ. អាស៊ាន
  - កា.រិ. បកប្រែ
  - កា.រិ អន្តរជាតិ.
  - កា.រិ. ពិធីការ
- **នាយកដ្ឋានកិច្ចការរដ្ឋបាល**
  - កា.រិ. រដ្ឋបាល និងរបៀប
  - កា.រិ. បុគ្គលិក
  - កា.រិ. ភស្តុភារ និងគណនេយ្យ
  - កា.រិ. តំកល់ឯកសារ
  - កា.រិ. ប្រតិបត្តិ
  - កា.រិ. គ្រប់គ្រងទីស្តីការ
- **នាយកដ្ឋានសរុប និងស្ថិតិ**
  - កា.រិ. សរុបកិច្ចការរដ្ឋបាលទូទៅ និងអធិការកិច្ច
  - កា.រិ. សរុបកិច្ចការសន្តិសុខ
  - កា.រិ. ស្ថិតិ
  - កា.រិ. ទំនាក់ទំនងព្រឹទ្ធសភា និងរដ្ឋសភា
  - កា.រិ. សារពត៌មាន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២.៦០០ លានរៀល ( ពីរពាន់ប្រាំមួយរយលានរៀល ) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងធនធានទឹក និង ឧតុនិយមសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទិញប្រេងឥន្ទនៈបំរើការងារបូមទឹកសង្គ្រោះស្រូវវស្សប្រាំង ឆ្នាំ ២០០១-២០០២ និង ស្រូវដើមរដូវវស្សា ឆ្នាំ ២០០២ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកា ចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៣.២១០ លានរៀល ( បីពាន់ពីររយដប់លានរៀល ) ពីជំពូក ៤០ (ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បោះពុម្ពតែមប្រ៉ឺតារី និង VISA STICKER ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤,០០០ លានរៀល ( បួនពាន់លានរៀលគត់ ) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌) របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់បំណុលថ្លៃផលិតអត្តសញ្ញាណបណ្ណ័ សញ្ជាតិខ្មែរ សងអោយក្រុមហ៊ុន ឈុន ហុង ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ករត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់លក្ខខ័ណ្ឌ និងលក្ខណៈវិនិច្ឆ័យចាំបាច់សំរាប់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យអំពីការបង្កើតសាកលវិទ្យាល័យ ។

# ជំពូកទី ២
# និយមន័យ លក្ខណៈទូទៅ និងវិធានបង្កើត

**មាត្រា ២.-**

សាកលវិទ្យាល័យជាស្ថាប័ន ដែលមានបេសកកម្មផ្តល់ការអប់រំបណ្តុះបណ្តាលធនធានមនុស្សចាប់ពីកំរិតបរិញ្ញាប័ត្រឡើងទៅ ធ្វើការស្រាវជ្រាវ និងធ្វើសហប្រតិបត្តិការជាតិ-អន្តរជាតិ លើគ្រប់វិស័យ ដូចជា វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ដើម្បីចូលរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និង ចូលរួមចំណែកលើកស្ទួយវប្បធម៌ជាតិ និងរក្សាអត្តសញ្ញាណជាតិ ។

**មាត្រា ៣.-**

សំណុំឯកសារសុំបង្កើតសាកលវិទ្យាល័យត្រូវដាក់ជូនក្រសួងអប់រំ យុវជន និងកីឡា ។
សំណុំឯកសារទាំងនោះរួមមាន :

- ផែនការយុទ្ធសាស្ត្រ សំរាប់ការអភិវឌ្ឍន៍គ្រឹះស្ថានឧត្តមសិក្សាសាម៉ី និងដើម្បីរួមចំណែកលើកស្ទួយវិស័យឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជា ។
- កម្មវិធីសិក្សាលំអិត រួមមានខ្លឹមសារ និងការរៀបចំ នៃកម្មវិធីសិក្សានោះ ។
- ការរៀបចំអភិបាលកិច្ចលំអិត រួមមានសមាជិកភាព និងវិធានការក្នុងការជ្រើសតាំងក្រុមប្រឹក្សាភិបាល ដើម្បីធានាអោយសមាជិកក្រុមប្រឹក្សាភិបាលមានតំណាង មកពីស្រទាប់សង្គមស៊ីវិល ។
- លក្ខខ័ណ្ឌ និងវិធានការក្នុងការជ្រើសតាំងសាកលវិទ្យាធិការ ។
- វិធានការរៀបចំសំរាប់ការគ្រប់គ្រងដ៏ត្រឹមត្រូវ ទៅលើទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ។
- សំណុំឯកសារលំអិតផ្សេងទៀត ដែលទាមទារដោយក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិនិត្យ និងវាយតំលៃ លើសំណុំឯកសារសុំបង្កើត ដើម្បីកំណត់នូវប្រភេទនៃគ្រឹះស្ថានឧត្តមសិក្សាអោយបានច្បាស់លាស់ ។ គ្រឹះស្ថានឧត្តមសិក្សា ដែលចេញសញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្រឡើងទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានពីរប្រភេទគឺ : សាកលវិទ្យាល័យ និង វិទ្យាស្ថាន ។

**មាត្រា ៥.-**

សាកលវិទ្យាល័យត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដូចតទៅ :

- ផ្តល់កម្មវិធីសិក្សាពហុជំនាញ ចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅ តាមរយៈមហាវិទ្យាល័យច្រើន
- ផ្តល់កម្មវិធីសិក្សា សំរាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដើម្បីចេញវិញ្ញាបនប័ត្រ នៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- ផ្តល់ការបង្រៀន ចំណេះដឹង និងការស្រាវជ្រាវ ដែលជាវិធានការក្នុងការលើកកំពស់ការយល់ដឹងរបស់និស្សិត និងបំផុសនូវចំណោទបញ្ហា និងការដោះស្រាយប្រកបដោយគតិបណ្ឌិត តាមវិធីសាស្ត្រទំនើប
- មានសាស្ត្រាចារ្យ ប្រកបដោយសមត្ថភាព និងបទពិសោធន៍
- មានបណ្ណាល័យ បន្ទប់ពិសោធន៍ សៀវភៅសិក្សា និងសំភារៈរូបវ័ន្តសមស្រប សំរាប់បំរើអោយការសិក្សានិងការស្រាវជ្រាវ
- មានទីតាំង អាគារ និងបន្ទប់រៀនសមស្របតាមនិយាមគរុកោសល្យ ។

**មាត្រា ៦.-**

រចនាសម្ព័ន្ធអប់រំ នៃសាកលវិទ្យាល័យមួយ គឺជាការប្រមូលផ្តុំនូវមហាវិទ្យាល័យច្រើន និងដេប៉ាតឺម៉ង់នានាសំរាប់ផ្តល់ការអប់រំ ចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅ ដែលមានរយៈពេលសិក្សាយ៉ាងតិចបីឆ្នាំ រឺច្រើនជាង ។ រចនាសម្ព័ន្ធនេះរួមមាន :

- មហាវិទ្យាល័យ គឺជាអង្គភាពអប់រំមួយ ដែលផ្តល់នូវកម្មវិធីអប់រំ ចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅនៅក្នុងមុខជំនាញច្រើន ដែលពាក់ព័ន្ធទៅនឹងផ្នែកឯកទេសផ្សេងៗ ។
- ដេប៉ាតឺម៉ង់ គឺជាអង្គភាពអប់រំមួយស្ថិតនៅក្នុងមហាវិទ្យាល័យ ដែលផ្តល់នូវកម្មវិធីអប់រំជាក់លាក់មួយ រឺមុខជំនាញមួយ ។

**មាត្រា ៧.-**

សាកលវិទ្យាល័យត្រូវមានមហាវិទ្យាល័យបីដូចខាងក្រោម :

- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម

និងយ៉ាងតិចត្រូវមានមហាវិទ្យាល័យបន្ថែមពីរផ្សេងទៀត ដែលផ្តល់នូវផ្នែកឯកទេសដូចខាងក្រោម :

- វិទ្យាសាស្ត្រសុខាភិបាល
- វិស្វកម្ម និងវិទ្យាសាស្ត្រកុំព្យូទ័រ

- នីតិសាស្ត្រ
- កសិកម្ម
- ស្ថាបត្យកម្ម និងរចនាប្លង់
- ការអប់រំ
- ការគ្រប់គ្រងពាណិជ្ជកម្ម
- ទូរគមនាគមន៍ (រាប់ទាំងការសិក្សាបណ្តាញពត៌មាន )
- ការសិក្សាអំពីបរិស្ថាន
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

វិស័យឯកទេសបន្ថែមផ្សេងៗទៀត ដែលអនុញ្ញាតដោយក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨.-**

មុខជំនាញខាងក្រោមនេះត្រូវបានរាប់បញ្ចូលទៅក្នុងមហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា :

- អក្សរសាស្ត្រ
- ប្រវត្តិសាស្ត្រ
- ទស្សនវិជ្ជា
- វិចិត្រសិល្បៈ
- តូរ្យតន្ត្រី
- បុរាណវិទ្យា
- ការសិក្សាអំពីសាសនា
- ខេមរសិក្សា
- ភាសាខ្មែរ
- ភាសាអង់គ្លេស
- ភាសាបារាំង
- ភាសាផ្សេងៗទៀត

មុខជំនាញខាងក្រោមនេះត្រូវបានរាប់បញ្ចូលទៅក្នុងមហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ :

- គណិតវិទ្យា
- គីមីវិទ្យា
- ជីវវិទ្យា
- រូបវិទ្យា
- ភូគព្ភសាស្ត្រ
- វិទ្យាសាស្ត្របរិស្ថាន
- វិទ្យាសាស្ត្រអនុវត្តន៍
- កុំព្យូទ័រវិទ្យា ។ល។

មុខជំនាញខាងក្រោមនេះ ត្រូវបានរាប់បញ្ចូលទៅក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម :

- វិទ្យាសាស្ត្រនយោបាយ
- រដ្ឋបាលសាធារណៈ
- សង្គមវិទ្យា និង នរវិទ្យា
- ចិត្តវិទ្យា
- សេដ្ឋកិច្ចវិទ្យា
- ភូមិវិទ្យា
- ប្រជាសាស្ត្រ ។ល។

មុខជំនាញនីមួយៗដែលមានចែងក្នុងមាត្រាខាងលើ បង្កើតបានជាមូលដ្ឋានគ្រឹះសំរាប់បង្កើត ដេប៉ាតឺម៉ង់មួយ រឺច្រើន ។ ការបន្ថែមមុខជំនាញផ្សេងៗទៀតលើមុខជំនាញខាងលើ ត្រូវមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩.-**

វិទ្យាស្ថានត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដូចតទៅ :

- ផ្តល់ការអប់រំ និងគុណវុឌ្ឍិចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅ តាមរយៈការបញ្ចូលគ្នានូវផ្នែកឯកទេសមួយ ឬច្រើន ដែលស្រង់ចេញពីបញ្ជីផ្នែកឯកទេសខាងក្រោម
- ផ្តល់ការបង្រៀន ចំណេះដឹង និងការស្រាវជ្រាវដែលលើកកំពស់ ការយល់ដឹងរបស់និស្សិត និងបំផុសនូវចំណោទបញ្ហា និងការដោះស្រាយប្រកបដោយគតិបណ្ឌិតតាមវិធីសាស្ត្រទំនើប

- មានសាស្ត្រាចារ្យ ប្រកបដោយសមត្ថភាព និងបទពិសោធន៍
- មានបណ្ណាល័យ បន្ទប់ពិសោធន៍ សៀវភៅសិក្សា និងសំភារៈរូបវិន្តសមស្រប សំរាប់បំរើអោយការសិក្សា និងការស្រាវជ្រាវ
- មានទីតាំងអាគារ និងបន្ទប់រៀនសមស្រប តាមនិយាមគរុកោសល្យ ។

**មាត្រា ១០.–**

វិទ្យាស្ថានអាចផ្តល់នូវកម្មវិធីអប់រំសំរាប់សញ្ញាប័ត្រ និងគុណវុឌ្ឍិ នូវផ្នែកឯកទេសដូចខាងក្រោម :

- វិទ្យាសាស្ត្រសុខាភិបាល
- វិស្វកម្ម និងវិទ្យាសាស្ត្រកុំព្យូទ័រ
- នីតិសាស្ត្រ
- កសិកម្ម
- ស្ថាបត្យកម្ម និងរចនាប្លង់
- អប់រំ
- ការគ្រប់គ្រងពាណិជ្ជកម្ម
- ទូរគមនាគមន៍ ( រាប់ទាំងការសិក្សាបណ្តាញពត៌មាន )
- ការសិក្សាអំពីបរិស្ថាន
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

វិមុខជំនាញផ្សេងៗទៀត ដែលអនុញ្ញាតដោយក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ១១.–**

ការបង្កើតសាកលវិទ្យាល័យរដ្ឋជាកម្មវត្ថុ នៃអនុក្រឹត្យបង្កើត រីឯការបង្កើតសាកលវិទ្យាល័យឯកជនជាកម្មវត្ថុនៃអនុក្រឹត្យទទួលស្គាល់ ។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំលក្ខខ័ណ្ឌ និងលក្ខណៈវិនិច្ឆ័យលំអិតសំរាប់ការបង្កើតសាកលវិទ្យាល័យ និងមានភារៈកិច្ចពិនិត្យ សំណុំឯកសារសុំបង្កើតសាកលវិទ្យាល័យ ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យសំរេច ។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ១២.-**

សាកលវិទ្យាល័យដែលកំពុងដំណើរការសព្វថ្ងៃ មានរយៈពេល ១០ ឆ្នាំ ( ដប់ឆ្នាំ ) ដើម្បីរៀបចំកែលំអអោយបានស្របទៅនិងលក្ខណៈវិនិច្ឆ័យដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ។

**មាត្រា ១៣.-**

សាកលវិទ្យាល័យដែលកំពុងដាក់ពាក្យសុំថ្មី មានរយៈពេល ០៣ ឆ្នាំ ( បីឆ្នាំ ) ដើម្បីរៀបចំកែលំអអោយបានស្របទៅ និងលក្ខណៈវិនិច្ឆ័យដូចបានកំណត់ក្នុងអនុក្រឹត្យនេះ បន្ទាប់ពីបានទទួលការយល់ព្រមរួចហើយពីរាជរដ្ឋាភិបាល ។

បើមានមូលហេតុសមស្របរយៈពេលរៀបចំកែលំអនេះ អាចពន្យារពេលបាន ០៣ ( បី ) ឆ្នាំទៀត ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួនអោយមានប្រសិទ្ធិភាព ។

**មាត្រា ១៥.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១៤
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- យោងតាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១** : អនុញ្ញាតអោយបង្កើត គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា" ស.ប.ស.ក" ។ សាកលវិទ្យាល័យនេះមានទីតាំងគោលនៅផ្ទះលេខ ១០ ផ្លូវ ២១៤ (សម្តេចប៉ាន) សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ និងមានសាខាពីរកន្លែងផ្សេងទៀតគឺ :

- សាខាទី១ :ស្ថិតនៅអាគារលេខ០៦ វិថីសម្តេចប៉ាន់ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ។

- សាខាទី២ :ស្ថិតនៅអាគារលេខ ៥៥ វិថី សម្តេចប៉ាន់ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ២** : សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាមាន ០៦ មហាវិទ្យាល័យ និងវិទ្យាស្ថានមួយ

១. មហាវិទ្យាល័យសិល្បៈ និង អក្សរសាស្ត្រ

២. មហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងសេដ្ឋសាស្ត្រ

៣. មហាវិទ្យាល័យកិច្ចការសាធារណៈ និងអន្តរជាតិ

៤. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងវិស្វកម្ម

៥. មហាវិទ្យាល័យអប់រំ

៦. មហាវិទ្យាល័យសិល្បៈ ផ្សព្វផ្សាយពត៌មានវិជ្ជា

៧. វិទ្យាស្ថានភាសាបរទេស

ទៅថ្ងៃអនាគត សាកលវិទ្យាល័យអាចបើកជំនាញឯកទេសផ្សេងៗទៀត និង សាលាដ៏ទៃទៀត ដោយរៀបចំសុំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣** : សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាមានបីកំរិតគឺ ថ្នាក់បរិញ្ញាប័ត្រ ថ្នាក់ម៉ាស្ទ័រ និង ថ្នាក់បណ្ឌិត

១.ថ្នាក់បរិញ្ញាប័ត្រ :មានរយៈពេលសិក្សាយ៉ាងតិច ៤ឆ្នាំ ដែលមានចំនួនក្រេឌីតយ៉ាងតិច ១២៨ ក្រេឌីត

២.ថ្នាក់ម៉ាស្ទ័រ : មានរយៈពេលសិក្សាយ៉ាងតិច ២ឆ្នាំ ដែលមានចំនួនក្រេឌីតយ៉ាងតិច៤២ក្រេឌីត

៣.ថ្នាក់បណ្ឌិត : មានរយៈពេលសិក្សាយ៉ាងតិច ៣ឆ្នាំដែលមានចំនួនក្រេឌីតយ៉ាងតិច ៥៤ក្រេឌីត

**មាត្រា ៤** : លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

១- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

២- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្របរិញ្ញាប័ត្រ រឺសញ្ញាប័ត្រដែលមានតំលៃស្មើ ។

៣- ថ្នាក់បណ្ឌិត : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រ ថ្នាក់ម៉ាស្ទ័រ ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

៤- បេក្ខជនត្រូវឆ្លងកាត់ការប្រលងតេស្ត ។

**មាត្រា ៥** : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាមានភារកិច្ច :

- ជ្រើសរើសសិស្ស និស្សិតអោយចូលរៀន និង ជ្រើសរើស សាស្ត្រាចារ្យមកបង្រៀន ។
- គ្រប់គ្រងអោយបានល្អ នូវការបង្រៀន ការងារស្រាវជ្រាវ ឯកសារសិក្សា ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូនក្រសួង អប់រំ យុវជន និង កីឡា រៀងរាល់ ឆមាស ។

**មាត្រា ៦ :** សាកលវិទ្យាល័យមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកគ្រប់គ្រងសាកលវិទ្យាល័យនេះ និងមានក្រុមប្រឹក្សាបណ្ឌិតសភាមួយ មានសមាជិកប្រាំរូបដែលមានសញ្ញាប័ត្រកិត្តិយសបណ្ឌិត សំរាប់ពិនិត្យ និងផ្តល់យោបល់ លើកម្មវិធីសិក្សានៅដើមឆ្នាំនីមួយៗ ។

**មាត្រា ៧ :** ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យលើការងារបណ្តុះបណ្តាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើសាកលវិទ្យាល័យនេះអនុវត្តខុសពីច្បាប់រដ្ឋ។

**មាត្រា ៨ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យនេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រ , ម៉ាស្ទ័រ និង បណ្ឌិតដែលផ្តល់អោយដោយសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បានបំពេញនិងអនុវត្តតាមនិយាមអប្បបរមា នៃការទទួលស្គាល់គុណភាពអប់រំថ្នាក់ឧត្តមសិក្សា ។

**មាត្រា ៩ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ១០ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីមុខការ"

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**....៥២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញលិខិតស្នើសុំ របស់លោក ជា ចំរើន ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** អនុញ្ញាតអោយបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា " សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា " ( CHAMROEUN UNIVERSITY OF POLY-TECHNOLOGY ) ហៅកាត់ជាភាសាខ្មែរ " ស.ច.ព " និងហៅកាត់ជាភាសាអង់គ្លេស " CUP " ។ សាកលវិទ្យាល័យនេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំងគោលស្ថិតនៅអាគារលេខ ៨៨ ផ្លូវលេខ ៣៥០

សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បណ្តុះបណ្តាលរយៈពេលខ្លី ក្រោម ២ឆ្នាំទៅតាមជំនាញវិជ្ជាជីវៈ ។
- ថ្នាក់បរិញ្ញាប័ត្ររងសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៧០ក្រេឌីត ។
- ថ្នាក់បរិញ្ញាប័ត្រសិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ។
- ថ្នាក់ម៉ាស្ទ័រសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីត ។
- ថ្នាក់បណ្ឌិតសិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ ត្រូវនឹង ៥៤ ក្រេឌីត ។

**មាត្រា ៣ :** សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាមាន :

១. មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ

២. មហាវិទ្យាល័យ វិទ្យាសាស្ត្របច្ចេកវិទ្យា និង គណិតវិទ្យាអនុវត្ត

៣. មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

៤. មហាវិទ្យាល័យ សណ្ឋាគារ និង ទេសចរណ៍

៥. មហាវិទ្យាល័យ មនុស្សសាស្ត្រ និង វិទ្យាសាស្ត្រនយោបាយ

៦. មហាវិទ្យាល័យ នីតិសាស្ត្រ

៧. មហាវិទ្យាល័យ កសិកម្ម និង អភិវឌ្ឍន៍ជនបទ

៨. មហាវិទ្យាល័យ ភាសាបរទេស

៩. មជ្ឈមណ្ឌលបណ្តុះបណ្តាលលេខាធិការ និង រដ្ឋបាល ។

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍ របស់សាកលវិទ្យាល័យ និង មានក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រមួយដែលសមាជិកក្រុមប្រឹក្សានេះមានសញ្ញាប័ត្រកិត្តិបណ្ឌិត សំរាប់ ពិនិត្យ និង ផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

-ថ្នាក់បរិញ្ញាប័ត្ររងៈបេក្ខជនទាំងពីរភេទបានបញ្ចប់ថ្នាក់ទី១២នៃមធ្យមសិក្សាចំណេះទូទៅយ៉ាងទាប។

- ថ្នាក់បរិញ្ញាប័ត្រៈ បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្របរិញ្ញាប័ត្រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

- សាកលវិទ្យាល័យត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើសអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦** : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាមានភារកិច្ច :

- ជ្រើសរើស សិស្ស-និស្សិត អោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៧** : និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យនេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះត្រូវបានផ្តល់អោយ ដោយសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះបានបំពេញនិងអនុវត្ត តាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ៩** : អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជ្រាប"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ២៣.៨៤២.....អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា ក្នុងខេត្តកំពង់ស្ពឺ មានដូចខាងក្រោម ៖

១- **សប្បុរសជននៃស្ថានទូតអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា** ជួយកសាងអាគារសិក្សា ០១ ខ្នង នៅសាលាបឋមសិក្សាតាំងរបង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សរុបទឹកប្រាក់ចំនួន ១២.០០០ USD ។

២- **សប្បុរសជននៃក្លឹបរ៉ូតារីភ្នំពេញ** ជួយកសាងទីចាត់ការ ០១ ខ្នង ព្រមទាំងបំពាក់សំភារៈសង្ហារឹម នៅសាលាបឋមសិក្សាអង្គប្រាសាទ ឃុំច្បារមន ស្រុកច្បារមន ខេត្តកំពង់ស្ពឺ សរុបទឹកប្រាក់ចំនួន ១១.៥០០ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៨៣ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការតែងតាំងនិងសំរួលភារកិច្ចមន្ត្រីរាជការ

*****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ស ំ រេ ច**

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោកស្រី **ទូត បញ្ញា** បច្ចុប្បន្នប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អោយទទួលភារកិច្ចជានាយខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយរក្សាឋានៈថ្នាក់ប្រធាននាយកដ្ឋាន ដដែល ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **អេង យេង** អតីតអគ្គទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំនួសលោកស្រី **ទូត បញ្ញា** ។

**មាត្រា ៣ :** អនុក្រឹត្យលេខ ១៩៦ អនក្រ.តត ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០ ស្ដីពីការតែងតាំងមន្ត្រីរាជការត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៨៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ឧត្តមសេនីយឯក **មាស សុភា** អគ្គមេបញ្ជាការរង និង ជាមេបញ្ជាការកងទ័ពជើងគោក ដែលបានបរិច្ចាគធនធាន ជួយកសាង និង អភិវឌ្ឍន៍ស្រុកឈូក និង ស្រុកជុំគិរី ខេត្តកំពត ចំណាយអស់ទឹកប្រាក់ចំនួន ២០៥.១០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ២៨៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

## សំរេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **HAYASHI TAMIO** សញ្ជាតិជប៉ុន ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងការអូសទាញជំនួយ រួមទាំងបរិច្ចាគថវិកាផ្ទាល់ខ្លួនផង បានចំនួន ៥៩១.០០០ ដុល្លារអាមេរិក សំរាប់ជួយដល់ប្រជាពលរដ្ឋកម្ពុជា ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៦៨៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## ស ម្រេ ច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគថវិកា ជួយកសាងផ្លូវលំ និង ព្រះវិហារវត្តអង្គរុន និង វត្តអង្គស្វែង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមាននាមខាងក្រោម ÷

១- ព្រះតេជគុណ **អោម ង៉ាន** ថវិកា ៤៤.៨៧០ USD

២- លោក **តែម មាស** ថវិកា ១១.៧០២ USD (នៅសហរដ្ឋអាមេរិក)

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៦៨៧ អនក្រ.បក - ១១

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានចំណាយធនធានផ្ទាល់ខ្លួន ជួយកសាងប្រាសាទព្រះគោ ០១ កន្លែង សំរាប់ជាទីសក្ការៈបូជា របស់ប្រជាពលរដ្ឋ នៅភូមិព្រៃឃ្មុំ ឃុំព្រៃឃ្មុំ ស្រុកកំពត ខេត្តកំពត ដូចមាននាមខាងក្រោម ÷

**ក.មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម **ហ៊ុន សាន** អគ្គនាយកកាំសាប ថវិកា ១១.០២៥ USD

២-លោក **លឹម គឹមសុខ** ទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋាន ថវិកា ១១.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

### ស ម្រេ ច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៤ រូប ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធផលនានា ក្នុងវត្តកំពង់នង់ ឃុំកូនសត្វ ស្រុកកំពត ខេត្តកំពត ដូចមាននាមខាងក្រោម ÷

| | | | | | |
|---|---|---|---|---|---|
| ១- លោក | **វ័ត្ត** | **សារឿន** | នៅភ្នំពេញ | ថវិកា | ១៨.០០០ USD |
| ២- លោក | **យក់** | **យ៉ន** | នៅភ្នំពេញ | ថវិកា | ១១.៥០០ USD |
| ៣- លោកស្រី | **តូច** | **សម្បត្តិ** | នៅភ្នំពេញ | ថវិកា | ១០.៨០០ USD |
| ៤- ឧបាសិកា | **ព្រំ** | **គីមហ៊ុន** | នៅឃុំកូនសត្វ | ថវិកា | ១០.២០០ USD |

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៦ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០០ / ១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- យោងតាមសំណើររបស់អាជ្ញាធរមីន

## សំ រេ ច

**មាត្រា១:** ត្រូវបានតែងតាំងមន្ត្រី នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ដូចខាងក្រោម:

១) លោក **ចៅ វេជ្ជា** ជាប្រធាននាយកដ្ឋានបទបញ្ញត្តិ និង នីតិកម្ម

២) លោក **ជា អឿង** ជាប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យ

៣) លោក **នេត សុផល** ជាប្រធាននាយកដ្ឋានផែនការ និង ត្រួតពិនិត្យ

៤) លោក **គួន ផេង** ជាប្រធាននាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិ-ការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន និង សាមុីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៧៩០.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / រកម / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ / អនក្រ / បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រី ០២ រូបដូចមានរាយនាម និងភារកិច្ចខាងក្រោម :

១-លោក **ហ៊ុយ សេដ្ឋ** ជាអគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល ។

២-លោក កើត មឿច ជាប្រធាននាយកដ្ឋានបុគ្គលិក ជំនួសលោក ទុំ ទិចិត្រ ដែលត្រូវផ្លាស់ទៅកាន់តំណែងផ្សេង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ លោក **ហ៊ុយ សេដ្ឋ** និងលោក **កើត មឿច** ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចំលងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧.៩១..អនក្រ. បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / រកម / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ / អនក្រ / បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- សេចក្តីសំរេចលេខ ៧០ សសរ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការព្យួរការងារមន្ត្រីរាជការ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ :** តែងតាំងលោក **អ៊ឹ ចិចិត្រ** ជាប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងសុខាភិបាល ក្រោយពីបានព្យួរការងារអោយនៅទំនេរគ្មានបៀវត្សរយៈពេល ០៦ ខែរួចហើយ ។

ប្រការ ២ ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងលោក អ៊ុំ ទិចិត្រ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចំលងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៩២ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាភិបាល
## ប្រចាំសាលាជាតិកសិកម្ម កំពង់ចាម

# រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការបង្កើតសាលាជាតិកសិកម្ម កំពង់ចាម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សំរេច

**មាត្រា ១:** ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំសាលាជាតិកសិកម្ម កំពង់ចាម ជាគ្រឹះស្ថានសារធារណៈរដ្ឋបាល ដែលមានរាយនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក សាន វណ្ណឌី | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ប្រធាន |
| ២- កញ្ញា នាយ សំនៀង | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

uk

៣- លោក ឈឹម សារ៉េត តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៤- លោក ម៉ុក ឆ៊ីន់ តំណាងក្រសួងអប់រំ យុវជន និង កីឡា សមាជិក

៥- លោក ឈាង សំណាង តំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៦- លោក ម៉ែន សុមិត្រ តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា សមាជិក

៧- លោក ហៃ ខួនលី តំណាងអភិបាលខេត្តកំពង់ចាម សមាជិក

៨- លោក សំ សារ៉ែន នាយកសាលាជាតិកសិកម្ម កំពង់ចាម សមាជិកស្វ័យប្រវត្តិ

៩- លោក ម៉ី លីហួត តំណាងក្រសួងធនធានទឹក និង ឧតុនិយម សមាជិក

១០- លោក ខេះ ម៉ុនថាន តំណាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម សមាជិក

១១- លោកស្រី គិត សុខខឹម តំណាងបុគ្គលិកសាលាជាតិកសិកម្ម កំពង់ចាម សមាជិក

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ សាលាជាតិកសិកម្ម កំពង់ចាម និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ នាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧៣ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** តែងតាំងលោក ចៅ ចណ្ណលី វរៈមន្ត្រី ថ្នាក់លេខ៥ អោយកាន់មុខតំណែងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៩៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកវរសេនីយឯក **អាត់ ខែម** ស្នងការនៃស្នងការដ្ឋាននគរបាល ខេត្តឧត្តរមានជ័យ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការកសាងអគារសំរាប់ធ្វើការចំនួន ១១ ខ្នង និង សមិទ្ធផលមួយចំនួនទៀត ជូនដល់កំលាំងនគរបាលខេត្តឧត្តរមានជ័យ ចំណាយអស់ទឹកប្រាក់ចំនួន ១២.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៩៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ទ៊ឹក ជុំ** ដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីកសាងព្រះវិហារ និង កែលំអសោភ័ណភាពទីធ្លា វត្តសិរីសុខារកាដុះ អស់ទឹកប្រាក់ចំនួន ២៨.៥០០ ដុល្លារអាមេរិក និង ៥៨.០០០.០០០ រៀល ស្ថិតនៅក្នុងឃុំក្រាំងតាយ៉ង ស្រុកពាមជរ ខេត្តព្រៃវែង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **អ៊ិន ឆាយ** ជាប្រធាននាយកដ្ឋានពត៌មានវិទ្យុផ្សាយទៅបរទេស អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពត៌មាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០២-១៤៥ ប្រក

**ប្រកាស**

**ស្តីពី**

**វិសោធនកម្មលើប្រកាសលេខ ធ ៧-០០-៥១ ប្រក**

**ស្តីពី**

**ចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់**
**និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ**

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ ៧-០០-៥១ ប្រក ស្តីពីចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ
- យោងតាមស្មារតីនៃការប្រជុំក្រុមការងារផ្នែកសេវាកម្មធនាគារនិងហិរញ្ញវត្ថុជាមួយវិស័យឯកជន នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២

**សំរេច**

**ប្រការ ១ :**

ធ្វើវិសោធនកម្មប្រការ៤ នៃប្រកាសលេខ ធ៧-០០-៥១ ប្រក ស្តីពីចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ ដែលមាន



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ខ្លឹមសារដូចខាងក្រោម :

កំរិតអប្បបរមាចាំបាច់នៃការធ្វើសំវិធានធនជាក់លាក់ ដោយផ្អែកលើចំណាត់ថ្នាក់ដែលពាក់ព័ន្ធត្រូវមានដូចខាងក្រោម :

បំណុលក្រោមស្តង់ដា : ១០% ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំលើកលែងតែសាច់ប្រាក់

បំណុលសង្ស័យ : ៣០% ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំលើកលែងតែសាច់ប្រាក់

បំណុលបាត់បង់ : ១០០% បើធនាគារអាចបង្ហាញភស្តុតាងជាក់ស្តែងតាមករណីនីមួយៗនូវទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំ និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។ ចំនួនឥណទានដែលពុំមានសំភារៈធានាត្រូវធ្វើសំវិធានធន ។

**ប្រការ ២ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និង ក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៣ :**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B.7.02...145...Prov Kor

# PRAKAS
**on**
**Amendment on Prakas No B 7-00-51**
**on**
**THE CLASSIFICATION AND PROVISIONING FOR BAD AND DOUBTFUL DEBTS, INCLUDING INTEREST IN SUSPENSE**

The Governor of the National Bank of Cambodia

With reference to the Constitution of the Kingdom of Cambodia;

With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the law on the Organization and Functioning of the National Bank of Cambodia;

With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions;

With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia;

With reference to the PRAKAS No B 7-00-51 on the Classification and Provisioning for Bad and Doubtful Debts, including Interest in Suspense;

Pursuant to the opinion of working group of banking and financial service with private sector on 5 February 2002.

Decides :

**Article 1** : Article 4 of Prakas No B 7-00-51 on the classification and provisioning for bad and doubtful debts, including interest in suspense, is amended and has the following content:

The mandatory minimum level of specific provisioning, depending on the classification concerned, shall be the following :

| | | |
|---|---|---|
| - Substandard | : | 10%, regardless of collateral value except cash, |
| - Doubtful | : | 30%, regardless of collateral value except cash, |
| - Loss | : | 100%, if the banks can prove the actual market value of collateral on the case by case basis, acceptable to the National Bank of Cambodia, only part of loan uncovered will be provisioned. |

**Article 2** : The General Direction, the General Secretariat, the General Inspection, the General Cashier and all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the NBC's supervisory authority shall strictly implement this Prakas.

**Article 3** : This Prakas shall have effect from the signing date.

Phnom Penh, , 2002

The Governor

cc:
- All members of the Board of Directors
- The parties concerned as stated in article 2
- File
- CM "for info"
- Administration Department of CM
  " for publication in the National Gazette "

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ ៧-០២-១៤៧ ប្រក

# ប្រកាស

## ស្តីពី

## វិសោធនកម្មលើប្រកាសលេខ ធ ៧-០១-១៣៧ ប្រក

## ស្តីពី

## ឥណទានចំពោះសម្ព័ន្ធញាតិ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ ៧-០១-១៣៧ ប្រក ស្តីពីឥណទានចំពោះសម្ព័ន្ធញាតិ
- យោងតាមស្មារតីនៃការប្រជុំក្រុមការងារផ្នែកសេវាកម្មធនាគារនិងហិរញ្ញវត្ថុជាមួយវិស័យឯកជន នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២

## សំរេច

**ប្រការ ១ :**

ធ្វើវិសោធនកម្មប្រការ៤ នៃប្រកាសលេខ ធ ៧-០១-១៣៧ ប្រក ស្តីពីឥណទានចំពោះសម្ព័ន្ធញាតិ ដែលមានខ្លឹមសារដូចខាងក្រោម ÷

សរុបឥណទានដក់សល់ថ្លឹងចំពោះសម្ព័ន្ធញាតិមិនត្រូវអោយលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធទេ ទោះជាក្នុងករណីណាក៏ដោយ ។ ការគណនាឥណទានសម្ព័ន្ធញាតិមិនត្រូវរួមបញ្ចូលការតំកល់ប្រាក់នៅទីស្នាក់ការកណ្តាល រឺនៅក្រុមហ៊ុនមេ ក្រោមល័ក្ខខ័ណ្ឌពីរដូចខាងក្រោម ÷

- ទីស្នាក់ការកណ្តាលេ ឬ ក្រុមហ៊ុនមេជាធនាគារ
- ត្រូវមានភស្តុតាងបង្ហាញថាធនាគារមានចំណាត់ថ្នាក់ស្មើ ឬខ្ពស់ជាង A⁻ តាមវិធីសាស្ត្រ Standard & Poor ឬតាមវិធីសាស្ត្រសមមូលដោយភ្នាក់ងារចាត់ថ្នាក់ដែលអន្តរជាតិទទួលស្គាល់ ។

ឥណទានដក់សល់ត្រូវគណនាទៅតាមប្រកាសស្តីពីអនុបាតសាធនភាព ( ប្រកាសបច្ចុប្បន្នលេខ ធ ៧-០០-៤៦ ប្រក ) ។

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារត្រូវគណនាស្របតាមប្រកាសស្តីពីការគណនាមូលនិធិ-ផ្ទាល់សុទ្ធរបស់ធនាគារ ( ប្រកាសបច្ចុប្បន្ន លេខ ធ ៧-០០-៤៧ ប្រក ) ។

**ប្រការ ២ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានអង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ៣ :**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០២

**ទេសាភិបាល**

ជា_ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B 7.02 – 146 Prorkor

# PRAKAS
# on
# Amendment on Prakas No B 7-01-137
# on
# LOANS TO RELATED PARTIES

---

**The Governor of the National Bank of Cambodia,**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26. 1996 promulgating the Law on the organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18. 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/ RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor of the National Bank of Cambodia;
- With reference to the Prakas No B7-01-137 on Loans to related parties;
- Pursuant to the opinion of working group of banking and financial service with private sector on 5 February 2002.

## DECIDES

**Article 1:** Article 4 of Prakas No B7-01-137 on Loans to related parties is amended and has the following content:

The total weighted outstanding of loans to related-parties will in no case be superior to 10% of the bank's net worth. The calculation of loans to related parties shall not includes the bank's placements with head office or mother company under two conditions:

- Head office or mother company is a bank;
- The evidence of its rating equal or superior to A⁻ according to Standard & Poor methodology, or equivalent, from an internationally recognized rating agency.

The outstanding of loans will be calculated according to the Prakas relating to the solvency ratio (currently B 7-00-46).

The bank's net worth will be calculated according to the prakas on the calculation of banks net worth (currently B 7-00-47).

**Article 2:** The General Direction, the General Secretariat, the General Cashier, the General Inspection, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the NBC's supervisory authority shall implement this Prakas.

**Article 3:** This Prakas shall have effect from the signing date

Phnom Penh, , 2002

**The Governor**

cc: - The Members of the Board of Directors
- CM "for information"
- Administration Department of CM "for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៨-០២-១៤៥ ប្រក

# ប្រកាស

## ស្តីពី

## រចនាសម្ព័ន្ធរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ

### ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈនស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈនស/រកត/០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមប្រកាសលេខ : ធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និង មុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០២

## សំរេច

**ប្រការ ១.-** រៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង កំណត់មុខងារ-ភារកិច្ចរបស់ការិយាល័យ និង ផ្នែកនៅក្រោមឱវាទ នៅក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២.-** នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ស្ថិតនៅក្រោមចំណុះអគ្គនាយកដ្ឋាន ហើយមានមុខងារ-ភារកិច្ចចំបងៗ គឺៈ



d2

- ពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ និងរាល់លិខិតបទដ្ឋានដែលពាក់ព័ន្ធ និង ការធ្វើបដិតុល្យរូបនីយកម្ម
- តាមដានការវិវត្តន៍នៃតម្លៃប្រាក់រៀលធ្វើជាមូលដ្ឋានកំណត់អត្រាប្តូរប្រាក់ជាផ្លូវការ និង ធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់
- គ្រប់គ្រងទុនបំរុងនៅក្រៅប្រទេស និង គណនីដែលបើកធ្វើទំនាក់ទំនងជាមួយធនាគារកណ្តាលក្រៅប្រទេស អង្គការអន្តរជាតិ និងធនាគារបរទេស និងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានការគ្រប់គ្រងជំនួយនិងបំណុលក្រៅប្រទេស
- រៀបចំបទបញ្ញា សារាចរណែនាំ ដើម្បីគ្រប់គ្រងអាជីវកម្មប្តូរប្រាក់លោហធាតុនិងត្បូងថ្មមានតម្លៃ ។

នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៣.-** រចនាសម្ព័ន្ធរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ត្រូវបានរៀបចំអោយមានការិយាល័យ៤នៅក្រោមឱវាទ ដូចមានរង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធ គឺ៖

១-ការិយាល័យបញ្ជូនសារ គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែករដ្ឋបាល
- ផ្នែកបញ្ជូននិងទទួលសារ ។

២-ការិយាល័យប្តូរប្រាក់ គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកគ្រប់គ្រងអត្រាប្តូរប្រាក់
- ផ្នែកគ្រប់គ្រងទុនបំរុងនៅក្រៅប្រទេស ( Front Office ) ។

៣-ការិយាល័យហិរញ្ញកិច្ច គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកហិរញ្ញកិច្ច ( Back Office )
- ផ្នែកប្រតិវេទន៍ ។

៤-ការិយាល័យលិខិតអនុញ្ញាត និងត្រួតពិនិត្យ គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកលិខិតអនុញ្ញាតអាជីវកម្ម
- ផ្នែកត្រួតពិនិត្យអាជីវកម្ម ។

ការិយាល័យនីមួយៗ ក៏ដូចផ្នែកនីមួយៗដែលនៅក្រោមចំណុះ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។



d 2

**ប្រការ ៤.–** ការិយាល័យបញ្ជូនសារមានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងការគ្រប់គ្រងឯកសារលេខសំងាត់ លេខកូដ និងការងារទទួលនិងបញ្ជូនសារតាមរយៈ SWIFT និង Telex រួមមានភារកិច្ចតាមផ្នែកដូចតទៅ៖

១ _ ផ្នែករដ្ឋបាល :

- តាក់តែង ចាត់បញ្ជូននិងរក្សាទុក នូវរាល់លិខិតឬឯកសារទាក់ទងផ្ទៃក្នុងក៏ដូចចេញទៅខាងក្រៅ
- ទទួល បញ្ជូនតាមមុខសញ្ញា និង រក្សាទុក នូវរាល់លិខិតឬឯកសារដែលផ្ញើចូល
- ដោះស្រាយ និង ផ្គត់ផ្គង់សំភារៈ-មធ្យោបាយបំរើការងារ តាមសេចក្តីត្រូវការជាក់ស្តែង
- គ្រប់គ្រងបញ្ជីវត្តមានមន្ត្រីបុគ្គលិក រៀបចំកម្មវិធីការងារសំរាប់ថ្នាក់ដឹកនាំនិងធានាពិធីការចំពោះភ្ញៀវនិងពិធីផ្សេងៗ
- គ្រប់គ្រងបៀវត្ស ជីវភាព សំណើតម្លើងឋានៈឬអតីតភាព ការដាក់វិន័យឬការលើកសរសើរ ចំពោះមន្ត្រីបុគ្គលិក តាមការជាក់ស្តែង
- កសាងគំរោងថវិកាប្រចាំគ្រាកំណត់ សំរាប់ទ្រទ្រង់ដំណើរការធនាគារទាំងមូល ។

២ _ ផ្នែកបញ្ជូននិងទទួលសារ :

- រក្សាទុកដោយមានសុវត្ថិភាព នូវឯកសារលេខសំងាត់ លេខកូដ របស់បណ្តាធនាគារនិងស្ថាប័នអន្តរជាតិដែលមានការទំនាក់ទំនង
- ត្រួតពិនិត្យថាត្រឹមត្រូវ នូវលេខសំងាត់ លេខកូដ របស់សារដែលបានទទួលនិងគិតលេខសំងាត់ លេខកូដ សំរាប់សារដែលធនាគារជាតិនៃកម្ពុជាត្រូវផ្ញើចេញ
- ទទួលបញ្ជូនសារចេញទៅក្រៅប្រទេស តាមរយៈប្រព័ន្ធ SWIFT និង Telex ក្រោយពីបានការចុះហត្ថលេខារបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា
- គ្រប់គ្រងម៉ាស៊ីន SWIFT និង Telex ។

**ប្រការ ៥.–** ការិយាល័យប្តូរប្រាក់មានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងការគ្រប់គ្រងអត្រាប្តូរប្រាក់ផ្លូវការនៃប្រាក់រៀល និង ចាត់ចែងវិនិយោគនូវទុនបំរុងនៅក្រៅប្រទេស រួមមានភារកិច្ចតាមផ្នែកដូចតទៅ៖

១ _ ផ្នែកគ្រប់គ្រងអត្រាប្តូរប្រាក់ :

- តាមដានការវិវត្តន៍នៃអត្រាប្តូរប្រាក់
- កំណត់អត្រាប្តូរផ្លូវការប្រចាំថ្ងៃ រវាងប្រាក់រៀលនិងដុល្លារអាមេរិក និងអត្រាប្តូរជាគោលរវាងរូបិយប័ណ្ណផ្សេងៗទៀត



៥ ៧

- សិក្សាវិភាគលើការវិវត្តន៍នៃរូបិយប័ណ្ណខ្លាំង ហើយស្វែងយល់ពីការវិវត្តន៍ប្រាក់រៀល ដើម្បីត្រៀមលក្ខណៈធ្វើអន្តរាគមន៍ទៅលើទីផ្សារប្តូរប្រាក់អោយមាន់ពេលវេលា
- អនុវត្តនូវកិច្ចការអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា លើទីផ្សារប្តូរប្រាក់ក្នុងស្រុក តាមរបៀបដាក់អោយដេញថ្លៃ ។

២ _ ផ្នែកគ្រប់គ្រងទុនបំរុងនៅក្រៅប្រទេស (Front Office) :

- សហការជាមួយផ្នែកហិរញ្ញកិច្ច(Back Office) ធ្វើប្រតិបត្តិការបណ្តាក់ទុន (Placement) នៃទុនបំរុងដែលមាន
- ធ្វើទំនាក់ទំនងជាមួយធនាគារបរទេស ដើម្បីបើកគណនីណូស្ត្រូ (Nostro)
- ធ្វើប្រតិបត្តិការបណ្តាក់ទុន ផ្អែកលើគំរូសក្ខីប័ត្រដែលមានពែងអំពីប្រភេទប្រតិបត្តិការ ទឹកប្រាក់អត្រាទិញលក់ ការបញ្ជាណែនាំសំរាប់ទូទាត់។ល។
- ធ្វើទំនាក់ទំនងជាមួយធនាគារកណ្តាលនិងស្ថាប័នហិរញ្ញវត្ថុបរទេស ដើម្បីរកគូបដិភាគសំរាប់ធ្វើប្រតិបត្តិការដាក់សន្សំឬសុំខ្ចី ប្រតិបត្តិការទិញ-លក់រូបិយប័ណ្ណ (Foreign Exchange) និង ប្រតិបត្តិការផ្សេងៗទៀត ដូចជា ស្វេប (Swap), អុបស៊ិន (Option) ជាដើម
- សហការយ៉ាងជិតស្និទ្ធជាមួយផ្នែកហិរញ្ញកិច្ច(Back Office) និងអគ្គបេឡា ដើម្បីដឹងយ៉ាងច្បាស់នូវចំនួនខ្វះឬចំនួនសល់នៃសាច់ប្រាក់រូបិយប័ណ្ណផ្សេងៗ ដើម្បីចាត់ការនាំចូលឬនាំចេញនូវរូបិយប័ណ្ណទាំងនោះ តាមការជាក់ស្តែង
- បង្កើតបញ្ជីធនាគារនិងបញ្ជីផ្សារហិរញ្ញវត្ថុ ដែលអាចធ្វើជាគូបដិភាគនិងបញ្ជីហានិភ័យនៃប្រទេសដៃគូ ហើយបញ្ជីនេះត្រូវសើរើជាប្រចាំដោយយោលទៅតាមសភាពការណ៍
- ប្រមូលផ្តុំស្ថិតិទាក់ទងនឹងបំណុលបរទេស
- តាមដានកាលវសាននិងការទូទាត់សងចំពោះបំណុលបរទេស
- តាមដាននិងកត់ត្រាការប្រើប្រាស់ជំនួយបរទេស របស់រាជរដ្ឋាភិបាល។

**ប្រការ ៦.-** ការិយាល័យហិរញ្ញកិច្ចមានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងការគ្រប់គ្រងនិងចុះកិច្ចបញ្ជិកាគណនីណូស្ត្រូ ( Nostro ) រួមមានភារកិច្ចតាមផ្នែកដូចតទៅ៖

១ _ ផ្នែកហិរញ្ញកិច្ច ( Back Office ) :

- ចុះបញ្ជីប្រចាំថ្ងៃអំពីលំហូរចូលនិងលំហូរចេញនៃរូបិយប័ណ្ណ ហើយនៅរាល់ចុងថ្ងៃ ត្រូវធ្វើការបិទបញ្ជីនៃរាល់គណនីណូស្ត្រូ (Nostro) សំរាប់គ្រប់ប្រភេទរូបិយប័ណ្ណ

- ផ្ញើការបញ្ជាក់ដោយ សារតាមរយៈ Telex SWIFT និង Fax ជាមួយធនាគារទំនាក់ទំនងបរទេស អំពីប្រតិបត្តិការធ្វើឡើងដោយផ្នែកគ្រប់គ្រងទុនបំរុងនៅក្រៅប្រទេស (Front Office)
- ផ្តល់សេវាទូទាត់នូវការចំណាយជារូបិយប័ណ្ណទៅក្រៅប្រទេស របស់រតនាគារជាតិ និងធនាគារពាណិជ្ជ
- ចុះបញ្ជិកាគណនេយ្យនានា និង ផ្តល់ទិន្នន័យពាក់ព័ន្ធទៅនាយកដ្ឋានគណនេយ្យនិងនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច
- ផ្ទៀងផ្ទាត់ ប្រៀបធៀបគណនីជាមួយសំរង់គណនីដែលទទួលបាន
- គ្រប់គ្រង និង ចុះបញ្ជិកាគណនេយ្យជាមួយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ( IMF )
- សហការជាមួយផ្នែកគ្រប់គ្រងទុនបំរុងនៅក្រៅប្រទេស (Front Office) ដើម្បីស្វែងរកធនាគារនិងទីផ្សារហិរញ្ញវត្ថុ សំរាប់ធ្វើជាដៃគូប្រតិបត្តិការ ជានាយកចិត្តទុកដាក់បញ្ចៀសហានិភ័យធនាគារនិងហានិភ័យនៃប្រទេសផងដែរ ។

២ _ ផ្នែកប្រតិវេទនី :

- ត្រួតពិនិត្យសំណុំឯកសារពាក់ព័ន្ធដល់ការនាំចេញឬផ្ទេរចេញនូវសាច់ប្រាក់ជារូបិយប័ណ្ណ របស់បណ្តាធនាគារពាណិជ្ជ
- ត្រួតពិនិត្យឯកសារសុំនាំចេញ-ចូលលោហធាតុ-ត្បូងថ្មមានតម្លៃរបស់ក្រុមហ៊ុនអាជីវកម្មមាសនិងផ្តល់ទិដ្ឋាការលើប្រតិវេទន៍ដែលមានលក្ខណៈត្រឹមត្រូវ
- ក្តាប់នូវស្ថានភាពរូបិយប័ណ្ណរបស់បណ្តាធនាគារពាណិជ្ជ សំដៅតាមដានចលនាពីការទិញ-លក់ពីការបង្វែរចេញ-ចូល ចំណូល-ចំណាយប្រាក់បញ្ញើ ឬការផ្តល់ឥណទាន និងសំដៅក្តាប់បានពីស្ថានភាពរូបិយប័ណ្ណតាមរយៈគណនីទំនាក់ទំនងក្រៅប្រទេស និង ស្ថានភាពបេឡា ។

**ប្រការ ៧.** ការិយាល័យលិខិតអនុញ្ញាតនិងត្រួតពិនិត្យមានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងការគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ លោហធាតុ និងត្បូងថ្មមានតម្លៃ រួមមានភារកិច្ច តាមផ្នែកដូចតទៅៈ

១ _ ផ្នែកលិខិតអនុញ្ញាតអាជីវកម្ម :

- ពិនិត្យសំណើសុំប្រកបអាជីវកម្មប្តូរប្រាក់ លោហធាតុនិងត្បូងថ្មមានតម្លៃ និងរៀបចំសំណុំបែបបទចេញលិខិតអនុញ្ញាតអាជីវកម្ម
- ពិនិត្យបន្តឡើងវិញ ឬក្នុងករណីមានកំហុសឆ្គង ព្យួរ ឬដកហូតលិខិតអាជីវកម្ម



d2

- ផ្សព្វផ្សាយប្រកាស-បទបញ្ជា-សារាចរណែនាំ-លិខិតជូនដំណឹង ។ល។ ដល់ប្រតិបត្តិករ-អាជីវករ
- ធ្វើស្ថិតិអាជីវកម្មប្តូរប្រាក់ អាជីវកម្មលោហធាតុនិងត្បូងថ្មមានតម្លៃ
- តាក់តែងលិខិតបទដ្ឋានទាំងឡាយ ដែលទាក់ទិនទៅនឹងរបបប្តូរប្រាក់ និងអាជីវកម្មខាងលើ ។

២ _ ផ្នែកត្រួតពិនិត្យអាជីវកម្ម :

- ត្រួតពិនិត្យ តាមដានការអនុវត្តន៍និងការគោរពតាមបទបញ្ញត្តិទាំងឡាយ ដែលធនាគារជាតិនៃកម្ពុជាបានកំណត់ ពាក់ព័ន្ធនឹងអាជីវកម្មប្តូរប្រាក់ លោហធាតុនិងត្បូងថ្មមានតម្លៃ
- ត្រួតពិនិត្យអំពីគុណភាពលោហធាតុនិងត្បូងថ្មមានតម្លៃ
- ត្រួតពិនិត្យនូវរាល់ប្រតិបត្តិការរបស់ផ្នែកគ្រប់គ្រងទុនបំរុងនៅក្រៅប្រទេស ( Front Office ) និងផ្នែកហិរញ្ញកិច្ច ( Back Office ) ផ្ទៀងផ្ទាត់ប្រតិបត្តិការនានាទៅនឹងបញ្ញត្តិជាធរមាន
- ផ្ទៀងផ្ទាត់ការចុះបញ្ជីគណនេយ្យ
- សរុបរបាយការណ៍អំពីប្រតិបត្តិការប្តូរប្រាក់របស់អាជីវកម្មប្តូរប្រាក់ និងចូលរួមសហការជាមួយនាយកដ្ឋានត្រួតពិនិត្យ ក្នុងការត្រួតពិនិត្យតាមដានធនាគារពាណិជ្ជដែលទាក់ទិនទៅនឹងប្រតិបត្តិការប្តូរប្រាក់ ។

**ប្រការ ៨.-** ក្រៅពីភារកិច្ចដែលមានចែងនូវរាល់ប្រការខាងលើនេះ ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និង ផ្នែកនីមួយៗ ត្រូវអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន ។

**ប្រការ ៩.-** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីបុគ្គលិកនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ត្រូវរក្សាដាច់ខាត់នូវការសម្ងាត់វិជ្ជាជីវៈ អនុលោមតាមមាត្រា១៦និងមាត្រា៧១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១០.-** រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១.-** អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងនាយកដ្ឋានសាមីត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១២.-** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

**កន្លែងទទួល :**

- ដូចប្រការ១១
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

................................................................

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាពត៌មាន "
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**ទេសាភិបាល**

**ជា ចាន់តូ**

ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុភាពលេខ
# ស្តីពី
# មុខងារ-ភារកិច្ចរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់

(ឧបសម្ព័ន្ធនៃប្រកាសលេខ : ធ៨០២-...១២៩..... ប្រក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០២-១៥០ ប្រ.ក

# ប្រកាស

ស្តីពី

## រចនាសម្ព័ន្ធរបស់នាយកដ្ឋានគណនេយ្យ
## និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ

### ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈនស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈនស/រកត/០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជារដ្ឋទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមប្រកាសលេខៈធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និង មុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០២

## សំរេច

**ប្រការ ១.-** រៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋានគណនេយ្យ និង កំណត់មុខងារ-ភារកិច្ចរបស់ការិយាល័យនិងផ្នែកនៅក្រោមឱវាទ នៅក្នុងប្រការបន្តបន្ទាប់ខាងក្រោម។

**ប្រការ ២.-** នាយកដ្ឋានគណនេយ្យស្ថិតនៅក្រោមចំណុះអគ្គលេខាធិការដ្ឋាន ហើយមានមុខងារ-ភារកិច្ចចំបងៗ គឺៈ



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- ត្រួតពិនិត្យឡើងវិញជាប្រចាំ នូវកិច្ចបញ្ជិកាគណនេយ្យដែលប្រមូលផ្ដុំពីគ្រប់នាយកដ្ឋាន-អង្គភាពជំនាញ ដើម្បីធានាការអនុវត្តន៍ត្រឹមត្រូវតាមរបបកំណត់និងប្រព័ន្ធគណនេយ្យ
- គ្រប់គ្រងតាមរយៈគណនេយ្យ នូវទ្រព្យសម្បត្តិនិងសម្ភារៈរបស់ធនាគារជាតិនៃកម្ពុជា (រាប់បញ្ចូលទាំងសាខាធនាគារជាតិនៃកម្ពុជា)
- ប្រមូលផ្ដុំទិន្នន័យគណនេយ្យ សិក្សា វិភាគ និងធ្វើរបាយការណ៍ជូនថ្នាក់លើ តាមតម្រូវការឬគ្រាកំណត់
- តម្លើងតារាងតុល្យភាពគណនី គណនីលទ្ធផល តារាងតុល្យការ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និង រួមទូទាំងបណ្ដាញ និងធ្វើការសិក្សាវិភាគលើឯកសារទាំងនេះ ។

នាយកដ្ឋានគណនេយ្យត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៣.-** រចនាសម្ព័ន្ធរបស់នាយកដ្ឋានគណនេយ្យត្រូវបានរៀបចំអោយមានការិយាល័យ៤ នៅក្រោមឱវាទ ដូចមានអង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធ គឺ៖

១- ការិយាល័យពិនិត្យអចិន្ត្រៃយ៍ គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកពិនិត្យសក្ខីប័ត្រមុនចុះបញ្ជី
- ផ្នែកផ្ទៀងផ្ទាត់ក្រោយចុះបញ្ជី និង ប្រៀបធៀបគណនី
- ផ្នែកទិន្នានុលេខន៍លិខិតយុត្តិការ ។

២- ការិយាល័យបញ្ជិកាសាខាធនាគារជាតិនៃកម្ពុជា គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកពិនិត្យគណនេយ្យសាខាធនាគារជាតិនៃកម្ពុជា
- ផ្នែកបញ្ជីសរុបសាខាធនាគារជាតិនៃកម្ពុជា ។

៣- ការិយាល័យគណនេយ្យទីស្នាក់ការកណ្ដាល គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកចុះបញ្ជិកានៅទីស្នាក់ការកណ្ដាល ( Head Office )
- ផ្នែកចុះបញ្ជិកាប្រតិបត្តិការក្រៅតារាង
- ផ្នែកតំឡើងតារាងតុល្យការទូទាំងធនាគារជាតិនៃកម្ពុជា ។

៤- ការិយាល័យហិរញ្ញកិច្ច-ថវិកា គ្រប់គ្រងផ្ទាល់នូវ :
- ផ្នែកគណនេយ្យគ្រប់គ្រងទ្រព្យសម្បត្តិ
- ផ្នែកគណនេយ្យ-ហិរញ្ញកិច្ចផ្ទៃក្នុង
- ផ្នែកគណនេយ្យថវិកា ។

ការិយាល័យនីមួយៗ ក៏ដូចផ្នែកនីមួយៗដែលនៅក្រោមចំណុះ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៤.-** ការិយាល័យពិនិត្យអចិន្ត្រៃយ៍មានមុខងារភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងការពិនិត្យសក្ខីប័ត្រនិងចុះបញ្ជីកុំព្យូទ័រនៅទីស្នាក់ការកណ្តាល រួមមានភារកិច្ចតាមផ្នែកដូចតទៅ ៖

១ _ ផ្នែកពិនិត្យសក្ខីប័ត្រមុនចុះបញ្ជី :

- ប្រមូលផ្តុំពីគ្រប់នាយកដ្ឋានដទៃទៀតនូវរាល់សក្ខីប័ត្រចុះបញ្ជីគណនេយ្យ (ឥណពន្ធនិងឥណទាន) និងសំណៅដើមដែលមាននៅក្នុងថ្ងៃប្រតិបត្តិការនីមួយៗ
- ធ្វើការត្រួតពិនិត្យឡើងវិញ ដើម្បីធានាភាពត្រឹមត្រូវនៃប្រតិបត្តិការនីមួយៗ ដោយផ្ទៀងផ្ទាត់អត្ថន័យប្រតិបត្តិការជាមួយរបបកំណត់គណនេយ្យ
- អនុវត្តវិធានការ ចំពោះលទ្ធផលជាក់ស្តែងនៃការត្រួតពិនិត្យប្រចាំថ្ងៃនោះ រួមមាន :
  - ចំពោះសក្ខីប័ត្រដែលត្រឹមត្រូវ : បំពេញការងារគណនេយ្យតាមលក្ខការណ៍វិលជុំបន្តទៅទៀត
  - ចំពោះសក្ខីប័ត្រខុសឆ្គងដោយភ័ន្តច្រឡំ : ស្នើអោយនាយកដ្ឋានសាមីធ្វើការកែតម្រូវទាន់ពេល
  - ចំពោះសក្ខីប័ត្រមិនទាន់មានតម្លាភាព : អាចធ្វើការសិក្សានិងផ្ទៀងផ្ទាត់ជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីកំណត់ឲ្យបានជាក់ស្តែងជាមួយចរិតប្រតិបត្តិការពិត និង/ឬជាមួយចំណារសំរេចរបស់ថ្នាក់ដឹកនាំ
  - ចំពោះសក្ខីប័ត្រដែលឆ្លុះបញ្ចាំងចេតនាល្មើសពិតៗ : ធ្វើរបាយការណ៍សម្ងាត់ ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានឬថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា តាមករណីជាក់ស្តែង ។

២ _ ផ្នែកផ្ទៀងផ្ទាត់ក្រោយចុះបញ្ជី និង ប្រៀបធៀបគណនី :

- ធ្វើការត្រួតពិនិត្យឡើងវិញរវាងការចុះបញ្ជីនៅក្នុងម៉ាស៊ីនកុំព្យូទ័រ ជាមួយនឹងសក្ខីប័ត្រចុះបញ្ជី ដែលបណ្តានាយកដ្ឋានផ្ញើមក
- ធ្វើការប្រៀបធៀបគណនីលំអិត រវាងនាយកដ្ឋានគណនេយ្យនិងបណ្តានាយកដ្ឋានដែលពាក់ព័ន្ធ ។

៣ _ ផ្នែកទិន្នានុលេខលិខិតយុត្តិការ :

- ចងក្រងទិន្នានុលេខលិខិតយុត្តិការប្រចាំថ្ងៃ និងថែរក្សាអោយគង់វង្សល្អ។

**ប្រការ ៥.-** ការិយាល័យគ្រប់គ្រងបញ្ជិកាសាខាធនាគារជាតិនៃកម្ពុជាមានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងបញ្ជីសរុប និង ការពិនិត្យតុល្យភាពសាខាធនាគារជាតិនៃកម្ពុជា រួមមានភារកិច្ចតាមផ្នែកដូចតទៅ ៖

១ _ ផ្នែកពិនិត្យគណនេយ្យសាខាធនាគារជាតិនៃកម្ពុជា :
- ពិនិត្យគណនេយ្យសាខាធនាគារជាតិនៃកម្ពុជា រៀងរាល់ខែ-ត្រីមាស-ឆមាស-ឆ្នាំ
- ធ្វើការប្រៀបធៀបរវាងតួលេខនៅទីស្នាក់ការកណ្តាល ( Head Office ) និងសាខា ( Branches ) រវាងគណនី NATBANK ។

២ _ ផ្នែកបញ្ជីសរុបសាខាធនាគារជាតិនៃកម្ពុជា :
- តម្លើងបញ្ជីសរុបទូទៅ របស់សាខាធនាគារជាតិនៃកម្ពុជា
- តម្លើងតុល្យភាពសរុប របស់សាខាធនាគារជាតិនៃកម្ពុជា
- ធ្វើរបាយការណ៍ពីសាច់ប្រាក់ឥណទាន និងប្រាក់បញ្ញើរបស់សាខាធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៦.-** ការិយាល័យគណនេយ្យទីស្នាក់ការកណ្តាលមានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទងទៅនឹងការចុះបញ្ជិកា ការតាមដានក្រៅតារាង និងតំឡើងតារាងតុល្យការ រួមមានភារកិច្ចតាមផ្នែកដូចតទៅៈ

១ _ ផ្នែកចុះបញ្ជិកាទីស្នាក់ការកណ្តាល ( Head Office ) :
- រៀបចំរបបកំណត់គណនេយ្យដោយផ្តើមចេញពីប្រព័ន្ធគណនីរបស់ធនាគារជាតិនៃកម្ពុជានិងណែនាំអោយនាយកដ្ឋាន-អង្គភាពនិងសាខាធនាគារជាតិនៃកម្ពុជាទាំងអស់យល់ដឹងច្បាស់លាស់ អាចទទួលខុសត្រូវបានក្នុងការកំណត់ខ្ទង់គណនី លើប្រតិបត្តិការដែលអនុវត្តរៀងៗខ្លួន
- ទទួលសក្ខីប័ត្រប្រចាំថ្ងៃ ពីការិយាល័យពិនិត្យអចិន្ត្រៃយ៍ ដើម្បីចុះបញ្ចូលទៅក្នុងកំព្យូទ័រ នូវបណ្តាប្រតិបត្តិការរបស់ទីស្នាក់ការកណ្តាល
- វាយតម្លៃឡើងវិញនៅដំណាច់ខែនីមួយៗ នូវរូបិយប័ណ្ណដែលបានចុះបញ្ជី។

២ _ ផ្នែកចុះបញ្ជិកាប្រតិបត្តិការក្រៅតារាង :
- ចុះបញ្ជីចំពោះប្រតិបត្តិការក្រៅតារាងនិងសន្និធិ ដូចជាក្រដាសប្រាក់បោះពុម្ពថ្មី មេដាយមាស ក្រដាសសំរាប់បោះពុម្ពប្រាក់ និង ផ្សេងៗទៀត ។

៣ _ ផ្នែកតំឡើងតារាងតុល្យការទូទាំងធនាគារជាតិនៃកម្ពុជា :
- បិទបញ្ជីប្រចាំថ្ងៃ
- សរុបតួលេខចំណូល-ចំណាយប្រចាំថ្ងៃ-ខែ-ឆ្នាំ ដើម្បីធ្វើរបាយការណ៍លទ្ធផលតាមគ្រា
- តំឡើងតារាងតុល្យការទូទាំងធនាគារជាតិនៃកម្ពុជាប្រចាំថ្ងៃ-ខែ-ឆ្នាំ ។

**ប្រការ ៧.-** ការិយាល័យហិរញ្ញកិច្ច-ថវិកាមានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទង ទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ហិរញ្ញកិច្ចផ្ទៃក្នុង និង ថវិកា តាមរយៈ គណនេយ្យ រួមមានភារកិច្ចតាមផ្នែកដូចតទៅ៖

១ _ ផ្នែកគណនេយ្យគ្រប់គ្រងទ្រព្យសម្បត្តិ :

- ចុះបញ្ជិកាពាក់ព័ន្ធនឹងចលនៈ-អចលនទ្រព្យរបស់ធនាគារជាតិនៃកម្ពុជា
- គិតគូរ និង ចុះបញ្ជិការំលស់ឬវាយតម្លៃឡើងវិញ នូវទ្រព្យសម្បត្តិទាំងនេះ
- ធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់ធនាគារជាតិនៃកម្ពុជា ។

២ _ ផ្នែកគណនេយ្យ-ហិរញ្ញកិច្ចផ្ទៃក្នុង :

- ពិនិត្យលើចំណូល-ចំណាយហិរញ្ញកិច្ចជាប្រក្រតីរបស់ទីស្នាក់ការកណ្តាល និង របស់សាខាធនាគារជាតិនៃកម្ពុជា ។

៣ _ ផ្នែកគណនេយ្យ-ថវិកាធនាគារជាតិនៃកម្ពុជា :

- ធ្វើការសិក្សា វិភាគ និង រួមផ្តល់មតិជាមួយខុទ្ទកាល័យ ពីគំរោងចំណូល-ចំណាយថវិកាប្រចាំត្រា សំរាប់ទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជា
- លើកសំណើបែងចែកលទ្ធផលប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា
- ពិនិត្យតារាងបៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗ ទីស្នាក់ការកណ្តាល និង សាខាធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៨.-** ក្រៅពីភារកិច្ចដែលមានចែងនៅរាល់ប្រការខាងលើនេះ ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និង ផ្នែកនីមួយៗ ត្រូវអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន ។

**ប្រការ ៩.-** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីបុគ្គលិកនាយកដ្ឋានគណនេយ្យ ត្រូវរក្សាដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ អនុលោមតាមមាត្រា១៦ និងមាត្រា៧១នៃច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១០.-** រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១១.-** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងនាយកដ្ឋានសាមីត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១២.-** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១... ខែ ... ឆ្នាំ ២០០២

**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល :**

- ដូចប្រការ១១

" ដើម្បីអនុវត្ត "

- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាពត៌មាន "

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិនៃកម្ពុជា

នាយកដ្ឋានគណនេយ្យ

# អង្គភាពលេខ
# ស្តីពី
# រចនាសម្ព័ន្ធរបស់នាយកដ្ឋានគណនេយ្យ

(ឧបសម្ព័ន្ធនៃប្រកាសលេខ : ធ៨០២-...១៤០.... ប្រក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២)

**នាយកដ្ឋានគណនេយ្យ**

- **ការិយាល័យ ពិនិត្យអចិន្ត្រៃយ៍**
  - ផ្នែក ពិនិត្យសក្ខីប័ត្រមុនចុះបញ្ជី
  - ផ្នែក ផ្ទៀងផ្ទាត់ក្រោយចុះបញ្ជី និងប្រៀបធៀបគណនី
  - ផ្នែក មិន្ទានុលេខន៍លិខិតយុត្តិការ
- **ការិយាល័យ បញ្ជិកាសាខាធនាគារជាតិនៃកម្ពុជា**
  - ផ្នែក ពិនិត្យគណនេយ្យសាខាធនាគារជាតិនៃកម្ពុជា
  - ផ្នែក បញ្ជីសរុបសាខាធនាគារជាតិនៃកម្ពុជា
- **ការិយាល័យ គណនេយ្យទីស្នាក់ការកណ្តាល**
  - ផ្នែក ចុះបញ្ជិកានៅទីស្នាក់ការកណ្តាល
  - ផ្នែក ចុះបញ្ជិកាប្រតិបត្តិការក្រៅតារាង
  - ផ្នែក តំឡើងតារាងតុល្យការទូទាំងធនាគារជាតិនៃកម្ពុជា
- **ការិយាល័យ ហិរញ្ញកិច្ច-ថវិកា**
  - ផ្នែក គណនេយ្យគ្រប់គ្រងទ្រព្យសម្បត្តិ
  - ផ្នែក គណនេយ្យហិរញ្ញកិច្ចផ្ទៃក្នុង
  - ផ្នែក គណនេយ្យថវិកា

2GRAGH.DOC.maly

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ១៧៧ MoC / M 2002

ភ្នំពេញ, ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០២

## ប្រកាស

## ស្តីពីការផ្ទេរទ្រព្យសម្បត្តិអចលនវត្ថុ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ៥៤អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

-បានឃើញការចាំបាច់របស់ក្រសួង

## ស ំ រេ ច

**ប្រការ១** : ផ្ទេរការគ្រប់គ្រងទីតាំងផ្ទះមួយល្វែងលេខ ៣៣២ អឺ០ ផ្លូវលេខ៣ ភូមិមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ជូនទៅ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( នាយកដ្ឋានកាំកុងត្រូល ) ជាអ្នកគ្រប់គ្រងវិញ ដោយផ្តាច់ចេញពីការគ្រប់គ្រង របស់មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ។

**ប្រការ២**: មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ត្រូវជំរះបញ្ជីអចលនវត្ថុខាងលើ ចេញពីបញ្ជីសារពើភណ្ឌរបស់ខ្លួន ព្រមជាមួយនោះ នាយកដ្ឋានកាំកុងត្រូល ត្រូវកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌអចលនទ្រព្យ របស់ខ្លួនដែរ ។

**ប្រការ៣**: នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ មន្ទីរពាណិជ្ជកម្មបាត់ដំបង នាយកដ្ឋានកាំកុងត្រូល ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម_ប្រសិទ្ធ**

**ចំលងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្តបាត់ដំបង

-ដូចប្រការ៣ "ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. [illegible] MoC / M 2002

## ប្រកាស

## ស្តីពីការបង្កើត

## គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើស

## សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- យោលតាមការចាំបាច់របស់ក្រសួង

## សំ រេ ច

**ប្រការ១ :** បង្កើតគណៈកម្មការ រៀបចំការបោះឆ្នោតជ្រើសរើស សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម រាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ខែក វ៉ាទី** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២- លោក **ស៊ន សុខណា** | អនុប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ | ជាអនុប្រធាន |

| | | |
|---|---|---|
| ៣- ឯកឧត្តម **សេង តុង** | អភិបាលរងរាជធានីភ្នំពេញ | ជាសមាជិក |
| ៤- លោក **កែ រិទ្ធី** | តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៥- លោក **សាម ម៉ុងហេង** | អគ្គនាយកសភាពាណិជ្ជកម្មរាជធានីភ្នំពេញ | ជាលេខាធិការ |

**ប្រការ២ :** គណៈកម្មការនេះ ត្រូវអនុវត្តការងារទៅតាមខ្លឹមសារទាំងឡាយ ដែលបានចែងអំពីភារៈកិច្ចរបស់គណៈកម្មការនៅក្នុងជំពូក២ នៃអនុក្រឹត្យ លេខ ៤២ អនក្រ.បក. ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្ដីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ។

**ប្រការ៣ :** បទបញ្ញត្តិទាំងឡាយណាដែលមានន័យផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤ :** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស សភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-សាលាក្រុងភ្នំពេញ
-ដូចប្រការ ៤
-ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

សាលាក្រុង ភ្នំពេញ

រាជធានីភ្នំពេញ, ថ្ងៃទី.០៦...ខែ មិថុនា.ឆ្នាំ២០០២

លេខ :..០៤៦..ប.ទ.ប្រក

## ប្រកាសរួម

## ស្តីពី

## ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យការប្រើប្រាស់រលកអាកាសវិទ្យុ

~~~~~~~~~~~~~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## និង

## ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស.រកត/១១៩៩/១៩១ ចុះថ្ងៃទី០៧/១១/៩៩ ស្តីពីការគ្រាស់បង្គាប់តែងតាំងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥អនក្រ ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ១៩៨៧ ស្តីពីប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦អនក្រ ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងប្រកាសរួម លេខ១០៥ប.ទប្រកចុះថ្ងៃទី០៥ ខែកញ្ញាឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រង និងបែងចែករលកអាកាសវិទ្យុ
- យោងសេចក្តីជូនដំណឹង លេខ០១២ សជណ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការប្រើប្រាស់រលកអាកាសវិទ្យុ
~~~~~~~~~~~~~~~~~~~~~~

- យោងប្រកាស លេខ៨០ បទ.ប្រក ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- យោងសារាចរ លេខ០៣ សរ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការពង្រឹងកិច្ចការពារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

- យោងសេចក្តីជូនដំណឹង លេខ ៣៥ បទ នគរអ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងប្រេកង់ជាតិ

- យោងស្មារតីអង្គប្រជុំ រវាងប្រតិភូក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាមួយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរងទី១ រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០០ ស្តីពីបញ្ហាការគ្រប់គ្រងរលកអាកាសវិទ្យុនិងបរិក្ខារវិទ្យុទាក់ទងគ្រប់ប្រភេទ ក្នុងរាជធានីភ្នំពេញ

- យោងស្មារតីអង្គប្រជុំឆ្លងពង្រាងប្រកាសរួម ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យ ការប្រើប្រាស់រលកអាកាសវិទ្យុ រវាងប្រតិភូក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និង ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរង រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០១

- យោងស្មារតីអង្គប្រជុំអចិន្ត្រៃយ៍គណៈអភិបាលរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមិនា ឆ្នាំ២០០២

- យោងការចាំបាច់ចំពោះមុខ

## <u>**សំរេច**</u>

**ប្រការ ១** :ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយមានឈ្មោះថា "**គណៈកម្មាធិការត្រួតពិនិត្យការប្រើប្រាស់រលកអាកាសវិទ្យុ**" ក្នុងក្របខ័ណ្ឌរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-**ឯកឧត្តម ត្រាក់ ថៃសៀង** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងរាជធានីភ្នំពេញ | **ប្រធាន** |
| ២-**ឯកឧត្តម ម៉ា សុផាន់ណា** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | **អនុប្រធាន** |
| ៣-លោក **មាស ប៊ុ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុ និង អាជ្ញាប័ណ្ណ | **សមាជិកអចិន្ត្រៃយ៍** |
| ៤-លោក **សេខ វណ្ណា** | ស្នងការរងនគរបាលរាជធានីភ្នំពេញ | **សមាជិក** |
| ៥-លោក **ជា សារិន** | មេបញ្ជាការរងកងរាជអាវុធហត្ថរាជធានីភ្នំពេញ | **សមាជិក** |
| ៦-លោក **អភិបាលខណ្ឌទាំង៧** | | **សមាជិក** |
| ៧-លោក **សុខ លក្ខិណា** | នាយខុទ្ទកាល័យរងសាលាក្រុងភ្នំពេញ | **សមាជិក** |
| ៨-លោក **សម្បត្តិ ណារិទ្ធ** | ប្រធានការិយាល័យវាស់ស្ទង់ប្រេកង់ | **សមាជិក** |
| ៩-លោក **ម៉ៅ កុលម៉ារឌី** | មន្ត្រីខុទ្ទកាល័យសាលាក្រុងភ្នំពេញ | **សមាជិក** |

**ប្រការ ២** : គណៈកម្មាធិការនេះមានភារៈកិច្ចដូចតទៅ :

ក- ត្រួតពិនិត្យបរិក្ខារដែលប្រើប្រាស់រលកអាកាសវិទ្យុទាំងអស់ក្នុងរាជធានីភ្នំពេញ ។

ខ- ធ្វើការដាក់ពិន័យចំពោះអ្នកប្រើប្រាស់បរិក្ខារដែលប្រើប្រាស់រលកអាកាសវិទ្យុគ្មានច្បាប់ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងរាល់ការតម្លើងបង្គោលអង់តែនរលកអាកាស ( ទូរសព្ទ័-វិទ្យុផ្សាយសំលេង និង ទូរទស្សន៍ ) ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងការអនុញ្ញាតលើទីតាំងពីសាលាក្រុងភ្នំពេញ។

គ- ធ្វើការដកហូតបរិក្ខារដែលប្រើប្រាស់រលកអាកាសវិទ្យុពីអតិថិជនណាដែលរឹងរូសពុំព្រមចូលខ្លួនមកធ្វើច្បាប់ប្រើប្រាស់ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីរៀបចំឯកសារបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។

ឃ- ត្រួតពិនិត្យច្បាប់ជួសជុល ច្បាប់ប្រើប្រាស់បរិក្ខារដែលប្រើប្រាស់រលកអាកាសវិទ្យុនៅតាមលំនៅដ្ឋាន រោងចក្រ សហគ្រាស ក្រុមហ៊ុន ស្ថាប័ននានា នៅតាមគ្រប់មធ្យោបាយធ្វើដំណើរនិងនៅតាមខ្លួនដែលកំពុងធ្វើចរាចរក្នុងរាជធានីភ្នំពេញ ។

**ប្រការ ៣** ៖ គណៈកម្មាធិការនេះត្រូវបង្កើតក្រុមការងារមួយដើម្បីជាជំនួយការក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុង ប្រការ២ ។

**ប្រការ ៤** ៖ គណៈកម្មាធិការត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលអនុវត្តឱ្យបានជាប់ជាប្រចាំរៀងរាល់ ខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ។

**ប្រការ ៥** ៖ គណៈកម្មាធិការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការនិងមានសិទ្ធប្រើប្រាស់ត្រារបស់សាលាក្រុងភ្នំពេញ។

**ប្រការ ៦** ៖ នាយកខុទ្ទកាល័យ និងប្រធាននាយកដ្ឋាន ចំណុះក្រសួង ប.ទ នាយខុទ្ទកា ល័យសាលាក្រុងភ្នំពេញ លោកអភិបាលខណ្ឌទាំង៧ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ ចំណុះសាលាក្រុងភ្នំពេញ ព្រមទាំងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ១ត្រូវអនុវត្តន៍ប្រកាសរួមនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| **ប្រតិភូរាជរដ្ឋាភិបាល** | **រដ្ឋមន្ត្រី** |
| **ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ** | **ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍** |
| ជា សុផារ៉ា | សូរ-ឃុន |

***កន្លែងទទួល:***

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពត៌មាន

" ដើម្បីជូនជ្រាបជាពត៌មាន "

- ដូចប្រការ៦" ដើម្បីអនុវត្ត"
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

Thouen / 2002

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
លេខ : ១៥៧ បទ.ប្រក.

ភ្នំពេញ, ថ្ងៃទី ០៧ ខែ ០៦ ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីការបង្កើតគណកម្មការ ដើម្បីត្រួតពិនិត្យការដឹកកប់ប្រព័ន្ធខ្សែកាប តាមនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- អនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- យោងលិខិតលេខ ២២៣ ល.ស ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០០ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- យោងលិខិតលេខ ០១៦៦/០២ រប ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២ របស់នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ
- បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណកម្មការមួយរបស់ក្រសួង ដែលមានសមាសភាពដូចខាងក្រោម :

១-លោក ឧទ៣ ទីរ: ប្រធានមជ្ឈមណ្ឌលថែរក្សា នៃ នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ប្រធាន

២-លោក **ហួត ណារិទ្ធ** មន្ត្រីនាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ អនុប្រធាន

៣-លោក **ហ៊ាន ជាទុធជា** ប្រធានមជ្ឈមណ្ឌល MCC នៃនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ សមាជិក

៤-លោក **ហ៊ាន ស៊ី** ប្រធានផ្នែករដ្ឋបាលបាយ័ន នៃនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ សមាជិក

៥-លោក **អ៊ុច គឹមនី** មន្ត្រីអធិការដ្ឋាន សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច ត្រួតពិនិត្យការបើកការដ្ឋានជីកកប់ប្រព័ន្ធទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលឆ្លងកាត់តាមនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ។ ក្រោយពេលចប់ភារកិច្ចត្រូវរាយការណ៍លទ្ធផលការងារជូន **ឯកឧត្តមរដ្ឋមន្ត្រី** ដើម្បីពិនិត្យ និង សុំយោបល់សំរេច ។

ប្រការ ៣ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ខុទ្ទកាល័យ-ធអិការដ្ឋាន-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៤ " ដើម្បីអនុវត្តន៍ "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

Thouen / 2002

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :......១៥៤......បទ.ប្រក

ភ្នំពេញ , ថ្ងៃទី០៧ ខែ០៦ ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីការបង្កើតគណកម្មការត្រួតពិនិត្យចំណូលចំណាយ អាជីវកម្ម សេវាកម្ម នៃមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ទូទាំងខេត្ត-ក្រុង

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- អនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញការងារចាំបាច់របស់ក្រសួង

## ស ំ រ េ ច

ប្រការ ១ : ត្រូវបានបង្កើតគណកម្មការមួយរបស់ក្រសួង ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | ត្រី ឆេង | ប្រធានធរិការដ្ឋាន | ប្រធាន |
| ២-លោក | កែវ ឧត្តរិន | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-លោក | ខេត ម៉ុន្ថា | ប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ៤-លោក | សរ រតនា | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ៥-លោក | ឡាយ ភ្លុក | អនុប្រធានការិយាល័យហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | ហេង គា | អនុប្រធានការិយាល័យអធិការកិច្ច | សមាជិក |
| ៧-លោក | ស៊ីន ម៉េងហោ | អនុប្រធានការិយាល័យអធិការកិច្ច | សមាជិក |

ប្រការ ២ : គណកម្មការនេះ មានភារកិច្ច ត្រួតពិនិត្យរាល់ការចំណូលចំណាយអាជីវកម្ម សេវាកម្ម លើវិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍ និងធ្វើការណែនាំពីនិតិវិធីការងារគណនេយ្យ-ហិរញ្ញវត្ថុ តាមបណ្តាមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ទូទាំងខេត្ត-ក្រុង ។ ក្រោយពេលចប់ភារកិច្ចត្រូវរាយការណ៍លទ្ធផលការងារជូន **ឯកឧត្តម រដ្ឋមន្ត្រី** ដើម្បីពិនិត្យ និង សុំយោបល់សំរេច ។

ប្រការ ៣ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ខុទ្ទកាល័យ-ធអិការដ្ឋាន-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ-គ្រប់មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ទូទាំង ខេត្ត-ក្រុង និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រដ្ឋមន្ត្រី

**កន្លែងទទួល**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៤ " ដើម្បីអនុវត្តន៍ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សភ
MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៤៧ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស
# ស្តីពី
# ការបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍ ដើម្បីអោយបានឈប់សំរាកបន្ថែមនារសៀលថ្ងៃសៅរ៍

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

# សំរេច

**ប្រការ១.-** ដើម្បីអោយបានឈប់សំរាកនារសៀលថ្ងៃសៅរ៍ បន្ថែមលើការឈប់សំរាកប្រចាំសប្តាហ៍ជាធម្មតានៅថ្ងៃអាទិត្យ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ អាចរៀបចំអោយកម្មករនិយោជិតធ្វើការតែប្រាំថ្ងៃកន្លះក្នុងមួយសប្តាហ៍។ ក្នុងករណីនេះ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចបង្កើនថិរវេលាធ្វើការពេញលេញរបស់កម្មករនិយោជិតដល់ប្រាំបួនម៉ោងជាអតិបរមាក្នុងមួយថ្ងៃ។

K

**ប្រការ២.-** ក្នុងការបែងចែកម៉ោងធ្វើការថ្មីនេះ បើការងារក្នុងសហគ្រាស គ្រឹះស្ថានបានរៀបចំឡើងជាពីរវេនបន្តបន្ទាប់គ្នា វេនទីមួយត្រូវបានសំរាកបន្ថែមនារសៀលថ្ងៃសៅរ៍ ហើយវេនទីពីរត្រូវបានសំរាកបន្ថែមនាព្រឹកថ្ងៃចន្ទ័នៃសប្តាហ៍បន្ទាប់ ។

**ប្រការ៣.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលមានបំណងបែងចែកម៉ោងធ្វើការរបៀបខាងលើ ត្រូវមានការឯកភាពជាមុន ជាមួយសហជីពដែលមានភាពជាតំណាង និងប្រតិភូបុគ្គលិក ឬជាមួយចំនួនពាក់កណ្តាល នៃកម្មករនិយោជិតតាមរយៈការបោះឆ្នោតជាសំងាត់ បើសហគ្រាស គ្រឹះស្ថានគ្មានប្រតិភូបុគ្គលិក និងសហជីព ។

**ប្រការ៤.-** បើមានការឯកភាពជាមួយ សហជីពដែលមានភាពជាតំណាង និងប្រតិភូបុគ្គលិក ឬកម្មករនិយោជិតរួចហើយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចអនុវត្តម៉ោងធ្វើការថ្មីមួយថ្ងៃបន្ទាប់ពីបានបិទផ្សព្វផ្សាយការបែងចែកម៉ោងធ្វើការថ្មីនេះនៅក្នុង សហគ្រាស គ្រឹះស្ថាន ។ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវជូនដំណឹងដល់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ឬនាយកដ្ឋានអធិការកិច្ចការងារ បើសិន ជាសហគ្រាស គ្រឹះស្ថាននោះ ស្ថិតនៅរាជធានីភ្នំពេញនៅមុនពេលអនុវត្តម៉ោងធ្វើការថ្មីនេះ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៨៩ សកអ. ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ

“ដើម្បីជូនជ្រាប”

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

“ដើម្បីផ្សព្វផ្សាយ និងអនុវត្ត”

-សមាគមនិយោជក
-សហព័ន្ធសហជីព

“ ដើម្បីជ្រាប ”

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ “ដើម្បីជួយផ្សព្វផ្សាយ”
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ : ១៤៣ សកបយ.

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស
# ស្តីពី
# ការបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតា ដោយគិតជាមធ្យមចំនួន១២សប្តាហ៍បន្តបន្ទាប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

# ស ម្រេ ច

**ប្រការ១.-** ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល ឬសេចក្តីត្រូវការជាចាំបាច់ក្នុងផលិតកម្ម ឬសេវាកម្ម ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ អាចបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតា ដោយយកចំនួនជាមធ្យម១២សប្តាហ៍បន្តបន្ទាប់មកគិត ។

៤

**ប្រការ២.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលចង់បែងចែកម៉ោងធ្វើការតាមរបៀបខាងលើនេះ ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :-

-ថិរវេលាធ្វើការគិតជាមធ្យមក្នុងរយៈពេល១២សប្តាហ៍បន្តបន្ទាប់ មិនត្រូវលើសពី ៤៨ ម៉ោងក្នុងមួយសប្តាហ៍

-ថិរវេលាធ្វើការប្រចាំថ្ងៃ មិនត្រូវលើសពីដប់ម៉ោង

-ការពន្យារថិរវេលាធ្វើការមិនត្រូវអោយលើសពីមួយម៉ោងក្នុងមួយថ្ងៃ ។

**ប្រការ៣.-** ក្រៅពីល័ក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ២ខាងលើ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវ :-

-ពិភាក្សាឯកភាពជាមុន ជាមួយសហជីពដែលមានភាពជាតំណាងនិងជាមួយប្រតិភូបុគ្គលិក ឬចំនួនពាក់កណ្តាលនៃកម្មករនិយោជិតយ៉ាងតិច ចំពោះសហគ្រាស គ្រឹះស្ថានដែលគ្មានប្រតិភូបុគ្គលិកនិងសហជីព

-ធានាការដឹកជញ្ជូនកម្មករនិយោជិតពីលំនៅដ្ឋាន ឬទីជិតខាងនៃលំនៅដ្ឋានរបស់កម្មករនិយោជិតទៅកន្លែងធ្វើការ និងត្រឡប់វិញ បើការធ្វើដំណើររបស់កម្មករនិយោជិតប្រព្រឹត្តទៅនៅពេលយប់

-ប្រើឧបករណ៍ស្វ័យប្រវត្តិដើម្បីចុចសលាកប័ត្រម៉ោងចេញ ចូលធ្វើការរបស់កម្មករនិយោជិតព្រមទាំងរក្សាទុកសលាកប័ត្រនេះរយៈពេលបីឆ្នាំ សំរាប់ការត្រួតពិនិត្យមើលជាយថាហេតុរបស់អធិការការងារ និងតុលាការការងារ ឬតុលាការអាជ្ញាកណ្តាល បើមិនទាន់មានតុលាការការងារ

-បិទផ្សាយម៉ោងធ្វើការថ្មីនៅក្នុងសហគ្រាស គ្រឹះស្ថាននិងត្រូវជូនដំណឹងដល់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត -ក្រុង នៃមូលដ្ឋានខ្លួន ឬនាយកដ្ឋានអធិការកិច្ចការងារ បើសហគ្រាស គ្រឹះស្ថានស្ថិតនៅរាជធានីភ្នំពេញ យ៉ាងហោចណាស់ប្រាំពីរថ្ងៃ មុនការដាក់អោយអនុវត្តម៉ោងធ្វើការថ្មីនេះ ។

**ប្រការ៤.-** ម៉ោងធ្វើការដែលលើសពី ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ត្រូវផ្តល់ប្រាក់ឈ្នួលតាមអត្រាតម្លើងដែលបានកំណត់ដោយមាត្រា ១៣៩ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ៨០ សកបយ.ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៩០ សកអ.ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
  និងយុវនីតិសម្បទា ខេត្ត-ក្រុង

  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

  "ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ : ១៤៤ សករបយ.

រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## បដិប្បញ្ញត្តិចំពោះការហាមឃាត់មិនអោយប្រើ ក្មេងធ្វើការពេលយប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ក្មេងដែលមានអាយុពី១៦ឆ្នាំទៅក្រោម១៨ឆ្នាំ អាចប្រើអោយធ្វើការនៅពេលយប់បាននៅក្នុងរោងចក្រស្លដែក និងដែកថែប រោងចក្រធ្វើកែវ រោងចក្រធ្វើក្រដាស រោងចក្រធ្វើស្ករ និងរោងចក្របំបែករ៉ែមាស ដែលត្រូវដើរឥតឈប់ទាំងយប់ទាំងថ្ងៃ។ ការប្រើក្មេងអោយធ្វើការពេលយប់នៅក្នុងរោងចក្រទាំងនេះមានគោលបំណងតែមួយគឺ ដើម្បីផ្តល់ការហ្វឹកហ្វឺន ឬបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្មេងតែប៉ុណ្ណោះ ។

**ប្រការ២.-** ក្នុងគ្រប់ករណីទាំងអស់ថិរវេលាធ្វើការប្រចាំថ្ងៃរបស់ក្មេង មិនអាចលើសពី ៨ ម៉ោងក្នុងមួយថ្ងៃ ហើយ

ការសំរាករបស់ក្មេងនៅចន្លោះពីម៉ោងធ្វើការមួយទៅម៉ោងធ្វើការមួយទៀត ត្រូវមានថិរវេលាយ៉ាងហោចណាស់ ១៣ ម៉ោងជាប់គ្នា ។

**ប្រការ៣.-** និយោជកដែលចង់ប្រើក្មេងពេលយប់ ត្រូវសុំការអនុញ្ញាតជាមុនពីអធិការការងារ ។ បន្ទាប់ពីបានទទួលពាក្យស្នើសុំហើយ អធិការការងារត្រូវធ្វើការសំរេចតាមករណីក្មេងនិមួយៗ ដោយផ្អែកតាមមូលហេតុ នៃការប្រើក្មេង ថិរវេលាធ្វើការ និងការសំរាករបស់ក្មេង ព្រមទាំងវិញ្ញាបនប័ត្រកាយសម្បទារបស់ក្មេង ដែលចេញដោយគ្រូពេទ្យការងារផង ។

**ប្រការ៤.-** នៅក្នុងគ្រឹះស្ថាន សហគ្រាសទាំងអស់ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ និយោជកអាចប្រើក្មេងប្រុសអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ អោយធ្វើការនៅពេលយប់បាន ដើម្បីជួយបង្ការគ្រោះថ្នាក់ដែលអាចនឹងកើតមាន ឬដើម្បីជួសជុលគ្រឿងចក្រ បរិក្ខា ឬសម្ភារៈដែលខូចខាតបណ្តាលមកពីមានគ្រោះថ្នាក់កន្លងមកហើយ ។ និយោជកដែលចង់ប្រើក្មេងក្នុងគោលបំណងខាងលើ ត្រូវជូនដំណឹងអោយអធិការការងារបានដឹងជាមុនអំពីមូលហេតុ នៃការធ្វើបដិប្បញ្ញត្តិនេះ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៨ សកអ.ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៘

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ : ១៤៥ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## ការហ្វឹកហ្វឺនវិជ្ជាជីវៈដល់ក្មេងសំរាប់ធ្វើការក្រោមដី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

# ស ំ រេ ច

**ប្រការ១.-** ក្មេងអាយុពី១៦ ឆ្នាំ ទៅក្រោម ១៨ ឆ្នាំ អាចប្រើអោយធ្វើការនៅអណ្តូងរ៉ែ ឬការយករ៉ែ ឬយកថ្មក្រោមដី បានតែក្នុងគោលបំណងហ្វឹកហ្វឺនវិជ្ជាជីវៈ និងជួយអោយក្មេងមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួនប៉ុណ្ណោះ ។ ការប្រើក្មេងក្នុងមុខរបរប្រភេទនេះ ត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌយ៉ាងតឹងរឹងដូចមានចែងក្នុងប្រការខាងក្រោម ។

**ប្រការ២.-** មុននឹងចូលធ្វើការ ក្មេងត្រូវទទួលការពិនិត្យកាយសម្បទាយ៉ាងម៉ត់ចត់ពីគ្រូពេទ្យការងារ រួមបញ្ចូលទាំងការថតសួតដោយវិទ្យុផង ។ ចំណាយលើការពិនិត្យកាយសម្បទាគឺជាបន្ទុករបស់និយោជក ។ វិញ្ញាបនប័ត្រកាយសម្បទា ដែលចេញដោយគ្រូពេទ្យការងារ ត្រូវរក្សាទុកដោយនិយោជក និងត្រូវបង្ហាញជូនអធិការការងារ ឬអធិការពេទ្យការងារតាមសំណើ ។ ការពិនិត្យកាយសម្បទានេះ ត្រូវធ្វើឡើងវិញរៀងរាល់រយៈពេល ៦ ខែ ។

**ប្រការ៣.-** និយោជកត្រូវមានសៀវភៅបញ្ជីសំរាប់ក្មេងដោយឡែកដែលក្នុងនោះត្រូវបញ្ជាក់ច្បាស់អំពី :-

-អាយុរបស់ក្មេង

-កាលបរិច្ឆេទ នៃការចុះក្រោមដីលើកទីមួយ

-ថិរវេលាសំរាកប្រចាំសប្តាហ៍

-ថិរវេលាសំរាកប្រចាំឆ្នាំ ។

**ប្រការ៤.-** មុននឹងចុះទៅធ្វើការក្រោមដី ក្មេងត្រូវទទួលការបណ្តុះបណ្តាលពិសេសដោយគ្រូស្ទាត់ជំនាញអំពី :-

-គ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាព និងសន្តិសុខការងារនៅក្រោមដី

-ការសង្គ្រោះបន្ទាន់

-វិធានការការពារគ្រោះថ្នាក់ ការប្រើប្រាស់បរិក្ខាសុវត្ថិភាព និងសេចក្តីណែនាំអំពីសន្តិសុខការងារ ។

**ប្រការ៥.-** ក្មេងដែលធ្វើការក្រោមដី ត្រូវតែស្ថិតក្រោមការដឹកនាំរបស់គ្រូបង្ហាត់ដែលមានការទទួលខុសត្រូវខ្ពស់ ។ ក្នុងករណីនេះក្មេងអាចជួយការងារក្នុងក្រុម ដើម្បីអោយមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួន ប៉ុន្តែពេលវេលាហ្វឹកហ្វឺនពិតប្រាកដយ៉ាងហោចណាស់ក៏ត្រូវស្មើនឹងពាក់កណ្តាលនៃពេលវេលាធ្វើការទាំងអស់របស់ក្មេងនៅក្រោមដីដែរ ។

**ប្រការ៦.-** ក្មេងដែលធ្វើការក្រោមដីមិនត្រូវទុកអោយធ្វើការដោយគ្មានការឃ្លាំមើលឡើយ ។ ហាមឃាត់មិនអោយប្រើក្មេងកាន់ឧបករណ៍គ្រឿងយន្តណា ឬប្រើប្រាស់នូវរបៀបធ្វើអាជីវកម្មណាដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់ក្មេង ។

**ប្រការ៧.-** ក្មេងមិនអាចធ្វើការនៅក្រោមដីលើសពី ៤០ ម៉ោង ក្នុងមួយសប្តាហ៍ ឬ ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។

**ប្រការ៨.-** ក្មេងដែលធ្វើការក្រោមដី ត្រូវបានឈប់សំរាកប្រចាំសប្តាហ៍ដែលមានថិរវេលាយ៉ាងហោចណាស់ ៤៨ ម៉ោងជាប់ គិតរួមបញ្ចូលទាំងថ្ងៃអាទិត្យ និងមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំចំនួន ២៤ ថ្ងៃ បើបានធ្វើការជាប់ក្នុងមួយឆ្នាំ ទោះបីជាការធ្វើការនៅក្រោមដីមានលក្ខណៈមិនពេញពេលក៏ដោយ ។

**ប្រការ៩.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៧ សកអ.ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១០.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ :...៤៥០.....អយក.ប្រក

# ប្រកាស
## ស្តីពី
## បទបញ្ជាជ្រើសរើសនិស្សិតអោយចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម. ០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- យោងប្រកាស លេខ ០១ អ.រ.ចតប្រ. ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពី បទបញ្ជាជ្រើសរើសនិស្សិតអោយចូលរៀន នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សា ឯកទេស ក្នុងប្រទេស និង ទៅសិក្សានៅបរទេស
- យោងលិខិតលេខ ៨២៤ សជណអ.រ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាល ស្តីពី ការយកលទ្ធផលពិន្ទុនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ សំរាប់ការជ្រើសរើស និង

ការប្រលងជ្រើសរើស សិស្ស និស្សិត ចូលរៀនគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសក្នុងប្រទេស និង ទៅសិក្សានៅបរទេស

**សំរេច**

ប្រការ ១ : គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវកំណត់ចំនួនជ្រើសរើសនិស្សិតអោយចូលរៀន អោយបានសមស្រប តាមនិយាមគរុកោសល្យ ។ ចំនួននេះ ត្រូវមាន ការឯកភាពយល់ព្រម ពីក្រសួងអាណាព្យាបាល ។ ការជ្រើសរើស ក៏ត្រូវយកចិត្តទុកដាក់ ចំពោះនិស្សិតក្រីក្រ និស្សិត មកពីតំបន់ដាច់ស្រយាល និង នារីភេទ ។

ប្រការ ២ : បេក្ខជនអាហារូបករណ៍ម្នាក់ៗ ដែលមានព្រឹត្តិប័ត្រពិន្ទុ អាចដាក់សំណុំពាក្យសុំចូលរៀនបានយ៉ាងច្រើនគ្រឹះស្ថានសិក្សាពីរ ដោយក្នុងនោះ មានបញ្ជាក់ពីគ្រឹះស្ថានសិក្សា ជាអាទិភាពទី១ និង អាទិភាពទី២ ។ បេក្ខជនមួយ នាក់ អាចបានទទួល អាហារូបករណ៍ តែមួយកន្លែង សំរាប់ការសិក្សា ក្នុងឆ្នាំសិក្សានីមួយៗ ។

ប្រការ ៣ : សិស្សពូកែ ទូទាំងប្រទេសប្រចាំឆ្នាំ ផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា ដែលបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិត្រូវបាន អនុញ្ញាតអោយបានទទួលអាហារូបករណ៍ចូលរៀនតាមគ្រឹះស្ថានឧត្តមសិក្សា ទៅតាមជំនាញ ពូកែរបស់ខ្លួន ។ សិស្សពូកែទាំងនេះត្រូវមកដាក់ពាក្យសុំចូលរៀននៅនាយកដ្ឋានឧត្តមសិក្សា ។

ប្រការ ៤ : ការជ្រើសរើសនិស្សិតអោយចូលរៀន មុខជំនាញនានា លើកលែង មុខជំនាញ ភាសាបរទេស សារគមនាគមន៍ និង សិល្បៈ នៅតាមគ្រឹះស្ថានឧត្តមសិក្សាមានពីររូបភាព :

- រូបភាពទី១ : ធ្វើការជ្រើសរើស ចំពោះបេក្ខជន ដែលមានព្រឹត្តិប័ត្រពិន្ទុ នៅពេលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។ ការជ្រើសរើសនេះ ធ្វើឡើងដោយផ្អែកលើនិទ្ទេសនៃមុខវិជ្ជាប្រលង និង ចំណាត់ថ្នាក់ របស់បេក្ខជន ។ ការជ្រើសរើស ក្នុងរូបភាពទី ១ អនុវត្តសំរាប់ជ្រើសរើស និស្សិតអាហារូបករណ៍ និង និស្សិតសិក្សាបង់ថ្លៃ ។ ចំនួននិស្សិតអាហារូបករណ៍ ត្រូវបែងចែក សំរាប់អ្នកពូកែ អ្នកក្រីក្រ អ្នករស់នៅតំបន់ដាច់ស្រយាល និង នារីភេទ ។
- រូបភាពទី២ : ធ្វើការជ្រើសរើសដោយឆ្លងកាត់ការប្រលងប្រជែង ចំពោះបេក្ខជនដែលពុំមានព្រឹត្តិប័ត្រពិន្ទុ ( បេក្ខជនជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមុនឆ្នាំ២០០២ ) ។

ប្រការ ៥ : ចំពោះមុខជំនាញ ដែលទាមទារសម្បទា រឺ ឧបនិស្ស័យខាងវិជ្ជាជីវៈ ដូចជា ភាសាបរទេស សារគមនាគមន៍ និង សិល្បៈ ការជ្រើសរើស ធ្វើឡើង ដូចខាងក្រោម :

- រូបភាពទី១ : ជ្រើសរើសដោយផ្អែកលើព្រឹត្តិប័ត្រពិន្ទុ នៅពេលប្រលងយកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនូវ មុខវិជ្ជាចំណេះទូទៅ និង ធ្វើការប្រលងនូវ មុខវិជ្ជាជំនាញ មួយ រឺ ពីរ មុខវិជ្ជា ( ភាសា . សិល្បៈ ) ។
- រូបភាពទី២ : ធ្វើការប្រលងជ្រើសរើស ទាំងមុខវិជ្ជា ចំណេះទូទៅ និង ជំនាញ ចំពោះបេក្ខជនជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មុនឆ្នាំ ២០០២ ។

ប្រការ ៦ : ក- មុខវិជ្ជាដែលត្រូវកំណត់យកជាមូលដ្ឋាន សំរាប់ការជ្រើសរើស ក្នុងរូបភាពទី១ និង រូបភាពទី ២ នៃប្រការ ៤ តាមមុខជំនាញឯកទេសនីមួយៗ មិនអោយលើសពី ៣មុខវិជ្ជាឡើយ ។

ខ- ការកំណត់ អាយុបេក្ខជន កំណត់ ប្រភេទមុខវិជ្ជា កំណត់ និទ្ទេស និង កំណត់ ចំណាត់ថ្នាក់ សំរាប់ការជ្រើសរើស និងការប្រលងប្រជែងជាសិទ្ធិរបស់គ្រឹះស្ថានសិក្សា នីមួយ ៗ ។

ប្រការ ៧ : បេក្ខជនដែលមានព្រឹត្តិប័ត្រពិន្ទុ ហើយពុំបានសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាក្នុងឆ្នាំ នេះអាចដាក់ពាក្យ សុំអោយធ្វើការជ្រើសរើសចូលរៀននៅឆ្នាំក្រោយៗទៀតបាន ។ ចំពោះបេក្ខជនដែលជាប់សញ្ញា ប័ត្រមធ្យមសិក្សាទុតិយភូមិមុនឆ្នាំ ២០០២ មានសិទ្ធិប្រលងយកអាហារូបករណ៍ចូលរៀននៅក្នុង គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ តែក្នុងឆ្នាំ ២០០២នេះ ប៉ុណ្ណោះ ប៉ុន្តែមានសិទ្ធិដាក់ពាក្យសុំ ប្រលងចូលរៀនក្នុងប្រភេទបង់ថ្លៃសិក្សា នាឆ្នាំនេះ និង ឆ្នាំក្រោយៗទៀតបាន ។

ប្រការ ៨ : ក- ការជ្រើសរើសនិស្សិត រូបភាពទី ១ ដូចក្នុងប្រការ ៤ ធ្វើឡើង ក្រោយពីគ្រឹះស្ថានសិក្សានីមួយៗ បានទទួលបញ្ជីឈ្មោះបេក្ខជន ដែលបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិដែល ក្នុងនោះ មានបញ្ជាក់ពី និទ្ទេសតាមមុខវិជ្ជា និង ចំណាត់ថ្នាក់ ពីនាយកដ្ឋានឧត្តមសិក្សា ។

ខ- ការប្រលងជ្រើសរើសនិស្សិតរូបភាពទី ២ ដូចក្នុងប្រការ ៤ មាន ២ ប្រភេទ :

ប្រភេទ ទី១ : ប្រលងជ្រើសរើសនិស្សិតអាហារូបករណ៍ដែលប្រព្រឹត្តទៅនៅដើម ខែ កក្កដា ឆ្នាំ ២០០២ ។

ប្រភេទ ទី២ : ប្រលងជ្រើសរើសនិស្សិតបង់ថ្លៃសិក្សាមាន ២ ដង អនុវត្តចំពោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង ឯកជន នឹងប្រព្រឹត្តទៅបន្ទាប់ពីការប្រលងជ្រើសរើសនិស្សិតអាហារូបករណ៍ ។

ប្រការ ៩ : ក្រសួង អប់រំ យុវជន និង កីឡា ត្រូវធ្វើការផ្សព្វផ្សាយ ដំណឹងជ្រើសរើសរួមអោយបានទូលំទូលាយ និង គ្រឹះស្ថានឧត្តមសិក្សានីមួយ ៗ ត្រូវធ្វើការផ្សព្វផ្សាយលំអិត ពីដំណឹងនៃការជ្រើសរើសរបស់ខ្លួន ។

ប្រការ ១០ : ចាប់ពីថ្ងៃប្រកាសផ្សាយដំណឹងបេក្ខជនម្នាក់ៗត្រូវមកដាក់សំណុំលិខិតផ្ទាល់ខ្លួននៅតាមគ្រឹះស្ថានសិក្សាដែលខ្លួនចង់រៀន ហើយសំណុំលិខិតនោះមាន :

- ពាក្យសុំចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបដែលមានបិទរូបថត ( ៤ គុណ ៦ ស.ម) ចំនួន ០២ ច្បាប់
  (ចំពោះបេក្ខជនមានព្រឹត្តិប័ត្រពិន្ទុ ប្រវត្តិរូបត្រូវមានការបញ្ជាក់ពីនាយកសាលា)
- សញ្ញាប័ត្រ រឺ វិញ្ញាបនប័ត្របញ្ជាក់ថាបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
  (ចំពោះបេក្ខជនមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មុនឆ្នាំ ២០០២) និងព្រឹត្តិប័ត្រពិន្ទុនៃការប្រលង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចំពោះបេក្ខជនមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចាប់ពីឆ្នាំ ២០០២ ចំនួន ០១ ច្បាប់ចេញអោយដោយនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ
- រូបថតក្នុងពេលថ្មី ទំហំ ( ៤ គុណ ៦) ចំនួន ៣ សន្លឹក

  ចំពោះបេក្ខជនដែលមានស្ថានភាពគ្រួសារក្រីក្រ និង អ្នករស់នៅពំបន់ដាច់ស្រយាល ហើយចង់បានអាទិភាពទទួលអាហារូបករណ៍ ត្រូវមាន ឯកសារពីរច្បាប់ថែមទៀតគឺ :
- សេចក្តីបញ្ជាក់ត្រឹមត្រូវពីរដ្ឋអំណាចថ្នាក់ឃុំ សង្កាត់ អំពីភាពក្រីក្រ និងអាស័យដ្ឋានរស់នៅតំបន់ដាច់ស្រយាល ។
- ប័ណ្ណគ្រួសារថតចំលងតាមផ្លូវច្បាប់ ០១ ច្បាប់ ។

ប្រការ ១១ : បេក្ខជនដែលផ្តល់ពតិមានមិនត្រឹមត្រូវ ភូតភរ នៅក្នុងសំណុំលិខិតផ្ទាល់ខ្លួននៅពេលដាក់ពាក្យសុំចូលរៀនត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជន ។ ក្នុងករណីរកឃើញនៅក្រោយ ពេលចូលរៀននោះ ត្រូវលុបឈ្មោះ ចេញពីបញ្ជីនិស្សិត ហើយ ប្រសិនបើបានប្រលងបញ្ចប់ការសិក្សាជាប់ ក្រសួងមិនប្រគល់សញ្ញាប័ត្រអោយឡើយ ។

ប្រការ ១២ : ចំពោះការជ្រើសរើសនិស្សិតអាហារូបករណ៍ ដូចក្នុង រូបភាពទី ១ នៃប្រការ៤គ្រឹះស្ថានសិក្សានីមួយៗ ត្រូវបង្កើតគណៈកម្មការជ្រើសរើសមួយ ដែលមានសមាសភាពដូចខាងក្រោម :

១-នាយកគ្រឹះស្ថានសិក្សា ជាប្រធាន

២-តំណាងក្រសួងអប់រំ យុវជន និង កីឡា មួយរូប ជាអនុប្រធាន

៣-តំណាងក្រសួងដែលជាអាណាព្យាបាល មួយរូប ជាអនុប្រធាន

៤-នាយករងទទួលបន្ទុកការសិក្សា មួយរូប ជាសមាជិក

៥-ព្រឹទ្ធបុរសមហាវិទ្យាល័យដែលមានការជ្រើសរើសនិស្សិត ជាសមាជិក

៦-ប្រធានការិយាល័យសិក្សា មួយរូប ជាសមាជិក និង ជាលេខា ។

គណៈកម្មការនេះ តែងតាំងដោយក្រសួងអាណាព្យាបាល និង ធ្វើការជ្រើសរើស ដោយផ្អែកលើគោលការណ៍ឯកភាព និង តាមចំនួនដែលបានកំណត់ ។ ក្នុងករណី ជ្រើសរើសបេក្ខជនមិនគ្រប់តាមចំនួន និង តាមលក្ខខណ្ឌកំណត់ គណៈកម្មការជ្រើសរើស អាចបញ្ចុះនិទ្ទេស រឺ បញ្ចុះចំណាត់ថ្នាក់ក្នុងកំរិតសមស្រប ដើម្បីធ្វើការជ្រើសរើសបន្ថែម អោយបានគ្រប់ចំនួនកំណត់ ។

គណៈកម្មការជ្រើសរើស អាចស្នើសុំបង្កើត អនុគណៈកម្មការ ផ្សេង ៗ ទៀត ជាជំនួយការក្នុង ការរៀបចំឯកសារ សំរាប់ការជ្រើសរើស ។

**ប្រការ ១៣** : នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅត្រូវផ្តល់លទ្ធផលនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ( បញ្ជីឈ្មោះសំរង់និទ្ទេសតាមមុខវិជ្ជា និងចំណាត់ថ្នាក់របស់បេក្ខជន ) មកនាយក - ដ្ឋានឧត្តមសិក្សា អោយបានមួយសប្តាហ៍យ៉ាងយូរក្រោយការប្រកាសលទ្ធផលប្រលង និងត្រូវផ្តល់ព្រឹត្តប័ត្រពិន្ទុរបស់បេក្ខជនម្នាក់ៗ អោយទៅបេក្ខជនសំរាប់ភ្ជាប់នៅក្នុងសំណុំពាក្យសុំចូលរៀន

**ប្រការ ១៤** : នាយកដ្ឋានឧត្តមសិក្សា មានភារកិច្ច :

១-សំរបសំរួលគ្រប់គ្រឹះស្ថានឧត្តមសិក្សា ដែលធ្វើការជ្រើសរើសនិងធ្វើការប្រលងជ្រើសរើស។

២-ផលិតបន្ថែមបញ្ជីឈ្មោះ សំរង់និទ្ទេសតាមមុខវិជ្ជា និង ចំណាត់ថ្នាក់របស់បេក្ខជន ដើម្បីចែកជូន គ្រប់គ្រឹះស្ថានឧត្តមសិក្សាដែលធ្វើការជ្រើសរើស ។

៣-រៀបចំលិខិតបទដ្ឋាន និង យន្តការនៃការជ្រើសរើស ការប្រលងជ្រើសរើសអោយប្រព្រឹត្តទៅបានល្អមានប្រសិទ្ធភាព និង តំលាភាព ។

**ប្រការ ១៥** : គណៈកម្មការនានា នៃការប្រលង យកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវមានសមាស- ភាពមន្ត្រី មកពី គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ នាយកដ្ឋានឧត្តមសិក្សា និងអង្គភាពពាក់- ព័ន្ធចូលរួម ។

**ប្រការ ១៦** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៧ :** អគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេសនិងវិជ្ជាជីវៈ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានដែលមានការពាក់ព័ន្ធ និង គ្រប់គ្រឹះស្ថានឧត្តមសិក្សា មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខា តទៅ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២

**ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**ប៊ុក ចន**

កន្លែងទទួល :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

-ក្រសួងសុខាភិបាល

-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

"ដើម្បីជូនជ្រាបជាពត៌មាន"

-គ្រប់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង

-គ្រប់វិទ្យាល័យក្នុងរាជធានីភ្នំពេញ

-ដូចក្នុងប្រការ១៧ "ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ